សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឡុង សុមនា**

លោក **លី ហ៊ុនលីន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឡុង សុមនា** និង **លី ហ៊ុនលីន** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី១៩ ឆ្នាំសិក្សា២០១៨-២០១៩។ ជាដំបូង ខ្ញុំសូមលំឱនកាយក្រាបប្រណិប័តន៍ និងសម្តែងការដឹងគុណយ៉ាងជ្រាវជ្រៅជូនចំពោះមាតាបិតាទាំងបួនរូបះ

លោកឪពុក **ឡុង ដាណារ៉ា** អ្នកម្តាយ **ខេង គីមជូ**

លោកឪពុក **ឈុន ហ៊ុនលី** អ្នកម្តាយ **សេង ចាន់ថុល**

ដែលលោកបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់អស់លោកនោះឡើយ និងបានឲ្យកូនរៀនសូត្រមានចំណេះដឹង រហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តដោយជោគជ័យ។ គុណូបក្ការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងបួន ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។

សូមគោរពថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្រ្តាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា ទាំងកម្លាំងកាយ កម្លាំងចិត្ត និងយកចិត្តទុកដាក់ បង្ហាត់បង្រៀនដល់ខ្ញុំបាទទាំងពីររូប រហូតបានបញ្ចប់ការសិក្សាដោយជោគជ័យ។ ជាពិសេសសូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត **ហាច់ ផល្លី** ដែលជាសាស្រ្តាចារ្យណែនាំ ដើម្បីធ្វើឲ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។

លើសពីនេះទៅទៀតសូមថ្លែងអំណរគុណដល់លោកប្រធាន អនុប្រធាន ថ្នាក់ដឹកនាំ ព្រមទាំង បុគ្គលិកទាំងអស់ នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ដែលបាន អនុញ្ញាតឲ្យខ្ញុំបាទទាំងពីរ បានចុះសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងសារណានេះ។ ពិសេស លោក **អ៊ុំ លីឃួរ** ដែលបានផ្តល់យោបល់ និងផ្តល់ឯកសារចាំបាច់ដល់ខ្ញុំទាំងពីរ។

ជាចុងក្រោយខ្ញុំបាទទាំងពីរនាក់ សូមជូនពរដល់លោកអ្នកមានគុណ លោក-លោកស្រីសាស្រ្តាចារ្យឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេលបួនឆ្នាំមកនេះដែលបានមកសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយសិក្សារៀនសូត្រនិងស្រាវជ្រាវដោយយកចិត្តទុកដាក់ ហើយបានសរសេរសារណាបញ្ចប់ឆ្នាំ សារណាមួយនេះ គឺជាស្នាដៃតូចមួយដែលកកើតឡើងជាពីការស្វែងរកស្រាវជ្រាវយកចិត្តទុកដាក់ វាបានកើតចេញពីការព្យាយាមយ៉ាងស្វិតស្វាញ និងការខិតខំប្រឹងប្រែងបំផុត អស់ពីកម្លាំងកាយចិត្ត ដែលបានបន្សល់ស្នាដៃមួយនេះឡើង ដើម្បីទុកជាទ្រព្យសម្បត្តិផ្នែកចំណេះដឹងទុកជាភស្តុតាងឆ្លុះបញ្ចាំងសម្ថភាពចំណេះដឹងទៅលើផ្នែកនីតិសាស្ត្រ។

ការលើកយកប្រធានបទស្ដីពី ការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល មកធ្វើការស្រាវស្រាវជ្រាវចងក្រង ជាសារណា គឺដោយសារខ្ញុំចង់ដឹងច្បាស់ពីរបៀប និងនីតិវិធីក្នុងការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល ក៏ដូចជាចង់ដឹងមានបញ្ហាប្រឈមអ្វីខ្លះដែលបានកើតឡើង នៅក្នុងការអនុវត្តចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាលនេះ។

ឯកសារនេះអាចនឹងមានភាពខ្វះចន្លោះជាក់ជាមិនខាន ទាំងអត្ថន័យ និងអត្ថរស ដោយសារសមត្ថភាពនៃការស្រាវជ្រាវរបស់ខ្ញុំនៅមានកម្រិត។ ដូច្នេះសូមមិត្តអ្នកអានមេត្តាអធ្យាស្រ័យចំពោះចំណុចខ្វះខាតដែលកើតមានឡើង ហេតុនេះហើយខ្ញុំសូមការអភ័យទោសពីសំណាក់ អ្នកទាំងអស់គ្នាដោយក្ដីអនុគ្រោះផង។

# មាតិកា

**សេចក្តីផ្តើម**........................................................................................................១

## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល

**១.១ សញ្ញាណសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា** ........................................................២
**១.១.១ ប្រវត្តិនៃកម្មសិទ្ធិ** ........................................................................................២
១.១.១.១ សម័យមុនអាណានិគមបារាំង ........................................................................២
១.១.១.២ សម័យអាណានិគមបារាំង ............................................................................៣
១.១.១.៣ សម័យឯករាជ្យ ......................................................................................... ៤
១.១.១.៤ សម័យកម្ពុជាប្រជាធិបតេយ្យ ......................................................................... ៤
១.១.១.៥ សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ........................................................... ៥
១.១.១.៦ សម័យរដ្ឋកម្ពុជា........................................................................................ ៥
១.១.១.៧ ព្រះរាជាណាចក្រកម្ពុជា................................................................................៧
**១.១.២ និយមន័យនៃកម្មសិទ្ធិ** ....................................................................................៧
**១.១.៣ ប្រភេទនៃកម្មសិទ្ធិ**..........................................................................................៧
១.១.៣.១ កម្មសិទ្ធិរដ្ឋ ............................................................................................. ៨
១.១.៣.២ កម្មសិទ្ធិសម្ហូភាព ..................................................................................... ៨
១.១.៣.៣ កម្មសិទ្ធិឯកជន .........................................................................................៩
**១.២ ប្រវត្តិនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា** ....................................................................... ១០

## ជំពូកទី២

## ការអនុវត្តចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល

**២.១ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ**...........................................................១៣

**២.១.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ** ........ ១៣

២.១.១.១ ការដាក់ពាក្យស្នើសុំ ........ ១៣

២.១.១.១ កិច្ចប្រតិបត្តិការបច្ចេកទេស ........ ១៥

ក.ការងារវាល ........ ១៥

ខ.ការងារការិយាល័យ ........ ១៧

២.១.១.៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ........ ១៨

២.១.១.៤ ការសម្រេចលើឯកសារ ........ ១៩

២.១.១.៥ ការចេញប័ណ្ណ ........ ២០

ក.តម្លៃសេវាសាធារណៈនៃការចុះបញ្ជី ........ ២២

**២.១.២ លទ្ធផលនៃការចុះបញ្ជី** ........ ២៤

**២.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ** ........ ២៤

**២.២.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ** ........ ២៥

២.២.១.១ ការត្រៀមរៀបចំ ........ ២៥

២.២.១.២ កិច្ចប្រតិបត្តិការបច្ចេកទេស ........ ២៦

ក.ការងារវាល ........ ២៧

ខ.ការងារនៅការិយាល័យ ........ ២៨

២.២.១.៣ ការបិទផ្សាយជាសាធារណៈនូវឯកសានៃវិនិច្ឆ័យ ........ ២៨

២.២.១.៤ ការសម្រេចលើឯកសារ ........ ២៩

២.២.១.៥ ការចេញប័ណ្ណ ........ ៣០

ក.តម្លៃសេវាសាធារណៈនៃការចុះបញ្ជី ........ ៣២

**២.២.២ លទ្ធផលនៃការចុះបញ្ជី** ........ ៣៣

**២.២.៣ ផលប្រយោជន៍នៃការចុះបញ្ជី** ........ ៣៣

## ជំពូកទី៣

## បញ្ហាប្រឈមនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល

**៣.១ ស្ថានភាពតំបន់ភូមិសាស្ត្រ** ........ ៣៤

**៣.២ ធនធានមនុស្ស** ........ ៣៤

**៣.៣ ហិរញ្ញវត្ថុ** ........ ៣៥

**៣.៤ ឧបករណ៍វាស់វែង** ........ ៣៦

**សេចក្តីសន្និដ្ឋាន** ........ ៣៧

**អនុសាសន៍** ........ ៣៨

**គន្ថនិទ្ទេស**

# សេចក្តីផ្តើម

រដ្ឋបានផ្តល់នូវឯកជនភាវូបនីយកម្មដីធ្លីដំបូងទៅដល់ប្រជាពលរដ្ឋនៅឆ្នាំ១៩៨៩។ រាជរដ្ឋាភិបាលបានសម្គាល់នូវបញ្ហាជាច្រើន ដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយបញ្ហាចម្បងនោះគឺ ការកាន់កាប់ដីធ្លី ដែលតម្រូវឲ្យរដ្ឋាភិបាលត្រូវដោះស្រាយជាបន្ទាន់ ដូចជា ជម្លោះ ក្នុងការដណ្តើមកានកាន់កាប់ដីធ្លីជម្លោះព្រំដី ការរំលោភយកដីប្រជាពលរដ្ឋពី សំណាក់អ្នមាន មានអំណាច និងការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម។ បញ្ហាទាំង នេះកើតចេញពី កង្វះខាតផ្នែកច្បាប់ ជាពិសេសភាពមិនច្បាស់លាស់ខាងផ្នែកច្បាប់លើសិទ្ធិដីធ្លី។ ដោយមើលឃើញនូវបញ្ហាបែបនេះទើបនៅក្រោយឆ្នាំ១៩៨៩ រដ្ឋាភិបាលបានរៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីសម្រួលដល់បញ្ហាចុះបញ្ជីដីធ្លីដូចជា ច្បាប់ភូមិបាលឆ្នាំ១៩៩២ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងច្បាប់ភូមិបាលឆ្នាំ២០០១ជាដើម។ ក្រោយមកទៀតមានការបង្កើត អនុក្រឹត្យផ្សេងៗ ដែលកំណត់ពីនីតិវិធីនៃការចុះបញ្ជីដីធ្លីលើកដំបូង ដូចជាការចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដើម្បីជំរុញប្រសិទ្ធភាពនៃដំណើរ ការផ្តល់កម្មសិទ្ធិលើដីធ្លីដល់ប្រជាពលរដ្ឋ។

តាមរយៈការលើកឡើងពីបញ្ហាខាងលើនេះ ក៏ដូចជាដើម្បីឲ្យមានការកំណត់ទិសដៅរបស់រាជរដ្ឋាភិបាលឲ្យមានស្ថិរភាពក្នុងសង្គម និងលើកស្ទួយជីវភាពប្រជាពលរដ្ឋទៀតផងនោះ ទើបលើកយកប្រធានបទមួយមកធ្វើការពិភាក្សា គឺ ការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណង ស្វែងយល់ពីខ្លឹមសារនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក៏ដូចជាដំណាក់កាលនីមួយៗនៃការចុះបញ្ជី និងជាពិសេសស្វែងរកផលវិបាកនានាក្នុងពេលអនុវត្តនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាលផងដែរ។ សារណានេះបែងចែកជាបីជំពូកគឺ។ ជំពូកទី១ បង្ហាញពីទិដ្ឋភាពទូទៅនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល។ ចំណែកជំពូកទី២ពិភាក្សាអំពីការអនុវត្តចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល។ រីឯជំពូកទី៣លើកយកពីបញ្ហាប្រឈម នៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល។

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល

## ១.១ សញ្ញាណសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅកម្ពុជា

ជាទូទៅកម្មសិទ្ធិដីធ្លីត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជីហើយកម្មសិទ្ធិនេះមានការប្រែប្រួល និងវិវត្តទៅតាមប្រវត្តិសាស្ត្រនិងបរិបទសង្គមមួយៗ។ ករណីនេះក៏មាននៅក្នុងប្រទេសកម្ពុជាផងដែរ ហេតុផលនេះជាការល្អ គប្បីសិក្សាអំពីប្រវត្តិនៃកម្មសិទ្ធិ(១.១.១) និយមន័យកម្មសិទ្ធិ(១.១.២) និងប្រភេទនៃកម្មសិទ្ធិ(១.១.១)។

### ១.១.១ ប្រវត្តិនៃកម្មសិទ្ធិ

សិទ្ធិលើកម្មសិទ្ធិដីធ្លីនិងការប្រើប្រាស់នៅលើធនធានដីធ្លី គឺកើតចេញមកពីការវិវត្តនៃចំណាត់ការជាប្រវត្តិសាស្ត្ររបស់សង្គមមនុស្សហើយក្នុងករណីសិទ្ធិនេះមិនត្រូវបានកំណត់ច្បាស់លាស់ទេ នោះនឹងនាំឲ្យមានវិវាទលើសិទ្ធិនេះកើតមានឡើង។ ការកំណត់សិទ្ធិលើដីធ្លី ការប្រើប្រាស់បែងចែក និងការទទួលខុសត្រូវលើធនធានដីធ្លីជាភាពចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេសឲ្យមានការរីកចម្រើន និងមានស្ថេរភាពក្នុងសង្គមជាតិ។ ចំពោះប្រវត្តិនៃកម្មសិទ្ធិ មានការវិវត្តទៅតាមសម័យកាលនីមួយៗដែលមានដូចជា សម័យមុនអាណានិគមបារាំង(១.១.១.១) សម័យអាណានិគមបារាំង(១.១.១.២) សម័យឯករាជ្យ(១.១.១.៣) សម័យកម្ពុជាប្រជាធិបតេយ្យ(១.១.១.៤) សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា(១.១.១.៥) សម័យរដ្ឋកម្ពុជា(១.១.១.៦) និងសម័យព្រះរាជាណាចក្រកម្ពុជា(១.១.១.៧)។[1]

#### ១.១.១.១ សម័យមុនអាណានិគមបារាំង

ពីមុន ព្រះមហាក្សត្រគឺជាម្ចាស់នៃដីទាំងអស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយសិទ្ធិភោគៈរបស់ប្រជារាស្ត្រលើដីធ្លីត្រូវបាន ទទួលស្គាល់ និងការពារ។ ក្នុងអំឡុងពេលនោះ សង្គមខ្មែរត្រូវបានបែងចែកជាវណ្ណៈផ្សេងៗគ្នាក្រៅពីញាតិវង្សានុវង្ស គឺមានវណ្ណៈសង្គមផ្សេងៗទៀតរួមមាន ក្សត្រា (អ្នកចម្បាំង) សមាជិកនៃក្រុម សាសនាផ្សេងៗ(ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា សាសនាតៅ)អ្នកដែលមានសេរីភាព និងទាសាទាសី។ ការបែងចែកវណ្ណៈក្នុងសង្គមបានធ្វើឲ្យប្រជាជនមានសិទ្ធិខុសៗគ្នាអាស្រ័យទៅតាមវណ្ណៈរបស់ខ្លួន។ ដូច្នេះនៅពេលនិយាយសំដៅដល់សិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់ដីធ្លី យើង មិនអាចសន្និដ្ឋានបានថាបុគ្គលគ្រប់រូបមានសិទ្ធិដូចៗគ្នានោះទេ។ សិទ្ធិនៃការកាន់កាប់ដីធ្លី អាចមានចំពោះតែសមាជិកមួយចំនួនក្នុងសង្គមតែប៉ុណ្ណោះ។ ប៉ុន្តែសម្រាប់ប្រជាជនដែលបានអាស្រ័យផលលើសិទ្ធិភោគៈ

[1] East-West Management Institute.Inc, ច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ, ២២។

សិទ្ធិនោះត្រូវបានទទួលស្គាល់នៅពេលដែលដីនោះត្រូវបានបង្កបង្កើនផល (រួមមាន ការរុករាន សង់ផ្ទះ ឬធ្វើរបង) ដោយគ្មានការអាក់ខាន និងមានការដឹងឮជាសាធារណៈ។ នៅពេលដែលប្រជាជនទទួលបានសិទ្ធិភោគៈលើដីហើយ សិទ្ធិភោគៈនោះអាចផ្ទេរបានតាមរយៈសន្តតិកម្ម ឬមតកសាសន៍ ហើយក៏អាចជាកម្មវត្ថុនៃកិច្ចសន្យាលក់ ឬជួលផងដែរ។ ក្រៅពីករណីលើកលែងមួយចំនួន សិទ្ធិនេះក៏អាចបាត់បង់ផងដែរ នៅពេលដែលដីនោះ ត្រូវបានបោះបង់ចោលក្នុងរយៈពេលបីឆ្នាំ។ ក្នុងករណីនេះ សិទ្ធិរបស់អ្នកកាន់កាប់ថ្មីត្រូវបានទទួលស្គាល់ ហើយភោគីដើមមិនមានសិទ្ធិទាមទារយកដីនោះមកវិញបានទេ។ ដើម្បីមានសិទ្ធិភោគៈលើដីដែលបានទទួលស្គាល់ជនម្នាក់ៗ មិនចាំបាច់ពាក្យ ឬធ្វើជាសេចក្តីប្រកាសទៅអាជ្ញាធរមូលដ្ឋានទេ។ ប៉ុន្តែត្រូវធ្វើសេចក្តីប្រកាសសម្រាប់ជាគោលបំណងនៃការបង់ពន្ធថ្វាយព្រះមហាក្សត្រ តាមច្បាប់ខ្មែរសម័យមុនមិនមានការបង់ពន្ធលើដីធ្លីដូចសម័យបច្ចុប្បន្ននេះទេ។ ផ្ទុយទៅវិញពន្ធក្នុងទម្រង់ជាសួយសារអាករត្រូវបង់ទៅលើភោគផលដំណាំដែលប្រមូលបានក្នុងឆ្នាំនីមួយៗ។ របបពន្ធដារគេមិនគិតទៅលើដីទេតែគិតតាមភោគផលដំណាំ គឺតាមសកម្មភាពបង្កបង្កើនផលកសិកម្ម។នៅក្នុងអំឡុងពេលប្រមូលភោគផល "អាជ្ញាហ្លួង" ឬមន្ត្រីរាជវាំងចុះតាមខេត្តនានា។ ក្នុងភូមិនីមួយៗ គេត្រូវប្រគល់បញ្ជីឈ្មោះរបស់កសិករ និងពាណិជ្ជករជូនទៅឲ្យអាជ្ញាហ្លួង ឬមន្ត្រីរាជវាំងទាំងនោះ។ តាមរយៈការប្រើប្រាស់បញ្ជីឈ្មោះទាំងនេះ អាជ្ញាហ្លួងវាយតម្លៃ ភោគផលដំណាំនៅនឹងកន្លែងរបស់ កសិករ ហើយកត់ត្រាចូលក្នុងសៀវភៅនូវពន្ធដែលកសិករជំពាក់។ ដូច្នេះ តាមច្បាប់ខ្មែរសម័យមុន ប្រជាជនធ្វើសេចក្តីប្រកាសទៅអាជ្ញាជាការចាំបាច់សម្រាប់គោលបំណងនៃការប្រមូលពន្ធដោយរដ្ឋ ប៉ុន្តែមិនតម្រូវឲ្យធ្វើសម្រាប់ទទួលស្គាល់សិទ្ធិភោគីលើដីនោះទេ។

### ១.១.១.២ សម័យអាណានិគមបារាំង

អនុសញ្ញា ឆ្នាំ១៨៨៤ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំងបានផ្ទេរ ឬប្រគល់អំណាចផ្នែករដ្ឋបាលរបស់រដ្ឋឲ្យទៅបារាំង។ ព្រះមហាក្សត្រស៊ីសុវត្ថិ ដែលឡើងគ្រងរាជសម្បត្តិក្នុងឆ្នាំ១៩០៦ បានរក្សាទំនាក់ទំនងយ៉ាងជិតស្និតជាមួយបារាំង ពេញមួយរជ្ជកាលរបស់ព្រះអង្គ។ នៅរជ្ជកាលនេះហើយ ដែលនៅក្នុងឆ្នាំ១៩២០ ក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានប្រកាសឲ្យប្រើ។ បទប្បញ្ញត្តិ ទាំងឡាយនៃក្រមរដ្ឋប្បវេណីនេះទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ[2] ដែលភាគច្រើនយកតាមក្រមរដ្ឋប្បវេណីរបស់បារាំង។ បទប្បញ្ញត្តិទាំងនេះចែងអំពីភាពខុសគ្នារវាងអចលនវត្ថុ និងចលនវត្ថុ និយមន័យនៃកម្មសិទ្ធិ និងសិទ្ធិភោគៈ។ ជាលទ្ធផលការអនុម័តក្រមរដ្ឋប្បវេណីនេះ បាន

[2] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "ទ្រព្យ" សំដៅលើវត្ថុ (អចលនវត្ថុ ឬចលនវត្ថុ)។

ធ្វើឲ្យច្បាប់ខ្មែរមុនៗស្តីពីទ្រព្យបានកែប្រែយ៉ាងច្រើន។ ឆ្លងតាមការអនុវត្តទស្សនៈច្បាប់បច្ចឹម ប្រទេសនេះ ព្រះមហាក្សត្រលែងមានសិទ្ធិធ្វើជាម្ចាស់លើដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀត ហើយ។ កម្មសិទ្ធិឯកជនត្រូវបានកំណត់ថាជាសិទ្ធិអាស្រ័យផល និងសិទ្ធិលក់ទ្រព្យសម្បត្តិ សិទ្ធិនេះជាសិទ្ធិដាច់ខាត និងផ្តាច់មុខ។ ប៉ុន្តែសិទ្ធិនេះត្រូវអនុវត្តក្នុងព្រំដែនកំណត់ និងលក្ខខណ្ឌច្បាប់។

មាត្រា៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានទទួលស្គាល់សិទ្ធិដាច់ខាត និងសិទ្ធិផ្តាច់មុខលើកម្មសិទ្ធិនេះ។ ទោះបីជាយ៉ាងណាក៏ដោយមានទស្សនៈមួយនៃច្បាប់ខ្មែរ ពីសម័យមុនត្រូវបានរក្សាទុកក្នុង ការបង្ហាញអំពីគោលការណ៍ច្បាប់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ទស្សនៈនេះមានការពាក់ព័ន្ធទៅនឹងតួនាទីនៃភោគៈក្នុងការទទួលស្គាល់សិទ្ធិរបស់ភោគីលើដីធ្លី។ ដូចបានលើកឡើងខាងលើពាក្យ "ភោគៈ" មាននិយមន័យពិសេសមួយរួចទៅហើយ អនុលោមតាមច្បាប់ខ្មែរសម័យមុនដែលបានទទួលស្គាល់ភោគៈនៃដីពេលដីនោះត្រូវបានបង្កបង្កើនផលនិងរុករានធ្វើរបង។ល។ ដោយសារកាលៈ ទេសៈទាំងនេះយើងអាចសន្និដ្ឋានបានថា អត្ថន័យដែលបានកំណត់សម្រាប់ពាក្យភោគៈក្នុងច្បាប់ ខ្មែរសម័យមុន ត្រូវបានប្រើប្រាស់ដើម្បីបកស្រាយបទប្បញ្ញត្តិនានានៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ការអនុម័តក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ គឺមានគោលបំណងអភិរក្សសុរិយោដីមជ្ឈការមួយ។ គោលបំណងនេះ គឺដើម្បីបង្កើនប្រពន្ធចុះបញ្ជីសុរិយោដីមួយទូទាំងប្រទេស ដែលការចុះបញ្ជីជាលាយលក្ខណ៍អក្សរ នឹងក្លាយជាភស្តុតាងនៃសិទ្ធិផ្សេងៗ ដូចជាកម្មសិទ្ធិ ភោគៈ ហ៊ីប៉ូតែក។ ប៉ុន្តែគោលបំណងនេះ មិនដែលសម្រេច ឬទទួលបានជោគជ័យទាល់តែសោះ ដោយសារតែប្រព័ន្ធនេះមិនត្រូវបានអនុវត្តទូទាំងប្រទេស។ នៅទីកន្លែងដែលមិនមានការិយាល័យ អភិរក្សសុរិយោដីម្ចាស់ដីត្រូវចុះបញ្ជីនៅទីស្នាក់ការឃុំ សង្កាត់។

### ១.១.១.៣ សម័យឯករាជ្យ

ក្រោមព្រះរាជបូជនីយកិច្ចរបស់ព្រះបាទនរោត្តម សីហនុ ប្រទេសកម្ពុជាបានទទួលឯករាជ្យក្នុងឆ្នាំ១៩៥៣។ ប៉ុន្តែប្រទេសកម្ពុជាជាប្រទេសដែលប្រើប្រព័ន្ធច្បាប់ Romano-Germanic អស់រយៈពេលជាង៣០ឆ្នាំ និងបន្តអភិវឌ្ឍន៍ជាលំដាប់។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនៅតែអនុវត្តក្នុងរយៈពេលនេះ។

### ១.១.១.៤ សម័យកម្ពុជាប្រជាធិបតេយ្យ

របបដីបានផ្លាស់ប្តូរយ៉ាងគំហុកពីឆ្នាំ១៩៧៥-១៩៧៩ ដែលជាសម័យកាលមួយស្ថិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាប្រវត្តិសាស្ត្រកម្ពុជាក្នុងសម័យនោះមិនមានច្បាប់ស្តីពីទ្រព្យសម្បត្តិទេ ហើយឯកសារនានា ក៏ត្រូវបានបំផ្លាញចោលអស់ដែរ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់។

អចលនវត្ថុរួមជាមួយមធ្យោបាយផលិតកម្មសំខាន់ៗទៅផ្សេងទៀតគឺជាទ្រព្យរបស់សមូហភាព។[3]

### ១.១.១.៥ សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា

សិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនមិនត្រូវបានទទួលស្គាល់ដោយច្បាប់ស្ទើរតែពេញអំឡុងពេលនៃរបបនេះ។ ប៉ុន្តែមានការកែទម្រង់ក្នុងឆ្នាំ១៩៨៩ មុនការអនុម័តរដ្ឋធម្មនុញ្ញថ្មីបន្តិច អនុក្រឹត្យ លេខ ២៥ ចុះថ្ងៃទី២២ ខែមេសាឆ្នាំ១៩៨៩ ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះសម្បែងជូនប្រជាជនត្រូវបាន អនុម័តឡើង។ មាត្រា១ នៃអនុក្រឹត្យនេះ ចែងអំពីប្រភេទនៃកម្មសិទ្ធិសមូហភាពលើដីលំនៅដ្ឋាន។ចំណែកមាត្រា២ នៃអនុក្រឹត្យបានធ្វើការកែប្រែយ៉ាងច្រើនដោយចែងថាប័ណ្ណកម្មសិទ្ធិលើផ្ទះសម្បែងអាចចេញជូនបុគ្គលម្នាក់ៗ ហើយប័ណ្ណលើផ្ទះសម្បែងនេះអាចធ្វើការផ្ទេរ តាមរយៈមតកសាសន៍ ឬការ លក់។

ក្រោយមកទៀត តាមរយៈការអនុម័តសេចក្តីណែនាំលេខ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តគោលនយោបាយប្រើប្រាស់ និងគ្រប់គ្រងដីធ្លី បានទទួលស្គាល់ កម្មសិទ្ធិលើដីលំនៅដ្ឋាន។ លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សិទ្ធិកម្មសិទ្ធិមិនមានចែងនៅក្នុងសេចក្តីណែនាំនេះទេ។ ចំពោះដីស្រែនិងដីកសិកម្ម មាត្រា១០ នៃសេចក្តីណែនាំនេះបានទទួល ស្គាល់សិទ្ធិភោគៈនៃជនដែលកាន់កាប់ និងប្រើប្រាស់ដីនោះ។ សេចចក្តីណែនាំនេះបានបញ្ជាក់ អះអាងជាគោលការណ៍ថា ភោគៈត្រូវតែពាក់ព័ន្ធជាពិសេសទៅនឹងការប្រើប្រាស់ដី។ សិទ្ធិភោគៈ ត្រូវបានទទួលស្គាល់ចំពោះដីស្រែនិងដីកសិកម្មដែលតិចជាង៥ (ប្រាំ) ហិកតា។ ចំពោះដីដាំដំណាំ គឺធំជាង៥ (ប្រាំ) ហិកតា សេចក្តីណែនាំនេះចែងអំពីភោគៈដែលបានផ្តល់ក្នុងទម្រង់ជាសម្បទាន។ នៅទីបំផុតយើងគួរបញ្ជាក់ផងដែរថា សេចក្តីណែនាំនេះមានគោលបំណងផងដែរនូវប្រព័ន្ធសម្រាប់ ការប្រកាសនិងការចុះបញ្ជីភោគៈ។

### ១.១.១.៦ សម័យរដ្ឋកម្ពុជា

ច្បាប់ភូមិបាលកម្ពុជាដំបូងបំផុតត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២។ កម្មសិទ្ធិដែលទទួលស្គាល់ទៅលើដីលំនៅដ្ឋានត្រូវបានចែងច្បាស់ថាជា "កម្មសិទ្ធិ គឺជាសិទ្ធិដែលច្បាប់បើកអោយអាស្រ័យ អោយចាត់ចែងនូវទ្រព្យណាមួយយ៉ាងផ្តាច់ការ និងផ្តាច់មុខតែម្នាក់ឯង កុំអោយតែយកវត្ថុនោះទៅ ប្រើប្រាស់ដោយបទងណាដែលខុសនឹងច្បាប់បានហាមហើយ។"[4] ច្បាប់ភូមិបាលឆ្នាំ ១៩៩២នេះបានស្តែងឲ្យឃើញពីការកើតមានឡើងវិញនូវកម្មសិទ្ធិឯកជនអនុលោមតាមច្បាប់កម្ពុជា។

[3] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ, ៥ មករា ១៩៧៦, មាត្រា២។

[4] ច្បាប់ភូមិបាល១៩៩២, លេខ១០០ ក្រ, ១០ សីហា ១៩៩២, មាត្រា១៩(២) (តទៅហៅថាច្បាប់ភូមិបាលឆ្នាំ១៩៩២)។

ប៉ុន្តែច្បាប់ភូមិបាលឆ្នាំ១៩៩២បានបញ្ជាក់ថា មានតែដីលំនៅដ្ឋានមួយគត់ ដែលអាចជាកម្មវត្ថុនៃកម្មសិទ្ធិឯកជន និងជាដីដែលស្ថិតក្នុងតំបន់ ទីក្រុង និងត្រូវបញ្ញត្តតាមច្បាប់ដោយឡែក។ ច្បាប់ស្តីពីការកំណត់តំបន់ទីក្រុងនៅមិនទាន់បាន អនុម័តនៅឡើយ។ ជាទូទៅច្បាប់ភូមិបាលឆ្នាំ១៩៩២ បានចែងឡើងវិញអំពីគោលការណ៍ច្បាប់នានា ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីមុនៗរបស់កម្ពុជា។ ច្បាប់នេះទទួលស្គាល់ការទទួល បានកម្មសិទ្ធិតាមរយៈសន្តតិកម្ម មតកសាសន៍ កិច្ចសន្យាលក់ ប្រទានកម្ម និងតាមរយៈភោគៈ។

អនុលោមតាមច្បាប់ភូមិបាលថ្មី២០០១ មធ្យោបាយដើម្បីទទួលបានដីជាគោលការណ៍គឺ មានតែតាមរយៈភោគៈ ដែលបានចាប់ផ្តើមកាន់កាប់មុនការចូលជាធរមាននៃច្បាប់ភូមិបាលឆ្នាំ២០០១។ ដោយសារហេតុនេះ កម្មវត្ថុនៃភោគៈក្រោមច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវតែធ្វើការបញ្ជាក់ ឲ្យបានល្អិតល្អន់ថែមទៀត។ ភោគៈត្រូវបានទទួលស្គាល់អនុលោមតាមផ្នែកទី២ (មាត្រា៦១-៧៦) នៃច្បាប់ភូមិបាលឆ្នាំ១៩៩២។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ បានអនុញ្ញាតឲ្យមានសិទ្ធិកម្មសិទ្ធិតាមរយៈភោគៈ។ ច្បាប់នេះក៏បានចែងផងដែរថា ដើម្បីក្លាយជាកម្មសិទ្ធិករនៃដី ភោគីត្រូវតែបង្ហាញថាភោគៈ របស់ខ្លួនគឺបានមកដោយ សន្តិវិធី សុចរិត មានការដឹងឮជាសាធារណៈ មិនមានការអាក់ខាន និងដោយគ្មានការបន្លំ។

លក្ខខណ្ឌទាំងនេះ ស្របទៅតាមទស្សនទានស្តង់ដាស្តីពីភោគៈ ក្នុងបណ្តាប្រទេសដែលអនុវត្តប្រព័ន្ធស៊ីវិល។ លើសពីនេះទៀតភោគៈត្រូវតែមានពេលវេលាយ៉ាងហោចណាស់៥ឆ្នាំក្នុងការកាន់កាប់ដីនោះ។ ទាក់ទងទៅនឹងការទទួលបានកម្មសិទ្ធិតាមរយៈភោគៈ ច្បាប់ភូមិបាល ឆ្នាំ១៩៩២ បានចែងនូវលក្ខខណ្ឌតម្រូវពីរផ្សេងទៀតគឺ ភោគីត្រូវជូនដំណឹងទៅសាលាឃុំ សង្កាត់ឲ្យបានដឹងឮ និងត្រូវបង់ពន្ធជាទៀតទាត់។[5]

លក្ខខណ្ឌតម្រូវទាំងនេះក៏មានចែងផងដែរនៅក្នុងមាត្រា៧១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ និងក្នុងមាត្រា៧១៣ នៃក្រមរដ្ឋប្បវេណីកែប្រែឆ្នាំ១៩៥១។ ទោះបីជាយ៉ាងណា មានកត្តាជា ច្រើនបានប៉ះពាល់ដល់ការអនុវត្តដោយសារតែការកែប្រែច្បាប់ភូមិបាល ឆ្នាំ១៩៩២។ បញ្ហាទី១៖ កម្រមានការចេញប័ណ្ណកម្មសិទ្ធិជូនប្រជាជនណាស់ ដូច្នេះប្រជាជនគ្រាន់តែបានចូលកាន់កាប់ដីតែប៉ុណ្ណោះ។ លើសពីនេះទៅទៀតការផ្លាស់ប្តូរទីកន្លែងច្រើនដងរបស់ប្រជាជន និងផលវិបាកក្នុងការចូលទៅដល់តំបន់មួយចំនួន បង្កឲ្យមានការប៉ះពាល់ដល់លទ្ធភាពអនុវត្តច្បាប់ភូមិបាលឆ្នាំ១៩៩២នេះ។ បញ្ហាទី២៖ មានការលំបាកក្នុងការផ្តល់ព័ត៌មានជូនប្រជាជនគ្រប់រូបអំពីកាតព្វកិច្ចតាមផ្លូវច្បាប់ថ្មី

[5] ច្បាប់ភូមិបាល១៩៩២, មាត្រា៦៥។

ស្តីពីការប្រកាសជូនដំណឹងពីភោគៈរបស់ខ្លួន និងការបង់ពន្ធទៀងទាត់។ ប្រសិនបើប្រជាជនមិនបានទទួលព័ត៌មាន ពួកគាត់មិនអាចអនុវត្តតាមកាតព្វកិច្ចថ្មីបានឡើយ ដូច្នេះតាមច្បាប់ពួកគាត់មិនអាចទាមទារកម្មសិទ្ធិលើដីដោយផ្អែកលើភោគៈរបស់ពួកគាត់បានទេ។ បញ្ហាទាក់ទងនឹងការប្រកាសអំពីភោគៈ និងការបង់ពន្ធនេះ គឺជាឧទាហរណ៍តែមួយប៉ុណ្ណោះ ស្តីពីបញ្ហាចោទដែលនឹងកើតឡើងពីច្បាប់ភូមិបាលឆ្នាំ១៩៩២ ហើយដែលជាហេតុនាំឲ្យមានសំណើកែប្រែជាច្រើន។ មានការកែប្រែច្រើនដងជាបន្តបន្ទាប់ រហូតដល់មានការអនុម័តច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ដែលពិភាក្សាខាងក្រោមនេះ។

#### ១.១.១.៧ ព្រះរាជាណាចក្រកម្ពុជា

នៅក្នុងឆ្នាំ១៩៩៣ដោយការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មីកម្ពុជាបានក្លាយជាព្រះរាជាណាចក្រមួយហើយបានបង្កើតឲ្យមានរដ្ឋាភិបាលថ្មី។ មាត្រា៤៤នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់សាជាថ្មីស្តីពី សិទ្ធិក្នុងការធ្វើជាម្ចាស់លើដីធ្លី ប៉ុន្តែកំណត់សិទ្ធិនេះចំពោះតែប្រជាជនកម្ពុជាប៉ុណ្ណោះ។ ក្រោយពីការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញច្បាប់ថ្មីនេះដើម្បីជំនួសច្បាប់ភូមិបាលឆ្នាំ១៩៩២ ហើយក៏បានប្រកាសឲ្យប្រើនៅ ឆ្នាំ២០០១ គឺច្បាប់ភូមិបាលឆ្នាំ២០០១។ ហើយការកាន់កាប់ភោគៈត្រូវបានបញ្ចប់នៅពេលដែលច្បាប់ ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន។[6] មានន័យថាអ្នកដែលបានកាន់កាប់ភោគៈមុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាននៅតែអាចបន្តកាន់កាប់បានទៀត ប៉ុន្តែបានបញ្ចប់នូវការចូលកាន់កាប់ភោគៈថ្មី ដែលមិនបានកាន់កាប់មុនច្បាប់នេះចូលជាធរមាន។

### ១.១.២ និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែង វត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរី នៅក្នុងទំហំដែលច្បាប់បានកម្រិត។[7] កម្មសិទ្ធិអាចរាប់បញ្ចូលទាំងសិទ្ធិប្រើប្រាស់សិទ្ធិអាស្រ័យផលនិងសិទ្ធិចាត់ចែងលើទ្រព្យ។ តាមផ្លូវច្បាប់កម្មសិទ្ធិកើតចេញពីការកាន់កាប់ស្របច្បាប់ឬការបានមកតាមផ្លូវច្បាប់ដូចជាតាមរយៈការទិញ ការដូរ ឬការឲ្យដោយស្របច្បាប់។

### ១.១.៣ ប្រភេទនៃកម្មសិទ្ធិ

ចាប់តាំងពីឆ្នាំ២០០១មកនៅពេលដែលច្បាប់ភូមិបាលត្រូវបានអនុម័តរាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនក្នុងការអភិវឌ្ឍគោលនយោបាយបទប្បញ្ញត្តិ និងការគ្រប់គ្រងក្របខណ្ឌ

[6] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២៩ (២) (តទៅហៅថាច្បាប់ភូមិបាលឆ្នាំ២០០១)។

[7] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១៣៨ (តទៅហៅថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

គតិយុត្តសម្រាប់ការរៀបចំដែនដី។ ចំពោះប្រភេទនៃកម្មសិទ្ធិដីមានបីធំៗ គឺកម្មសិទ្ធិរដ្ឋ (១.១.៣.១) កម្មសិទ្ធិសមូហភាព (១.១.៣.២) និងកម្មសិទ្ធិឯកជន (១.១.៣.៣)។

### ១.១.៣.១ កម្មសិទ្ធិរដ្ឋ

កម្មសិទ្ធិរដ្ឋចែកចេញជាពីរប្រភេទគឺៈ កម្មសិទ្ធិសាធារណៈរបស់រដ្ឋសំដៅទៅរាល់ដីទាំងឡាយណាដែលបម្រើឲ្យផលប្រយោជន៍សាធារណៈ។ ទាំងនេះរាប់បញ្ចូលទាំងៈ ទ្រព្យដែលមានប្រភពពីធម្មជាតិ (ដូច ជាព្រៃឈើ ទន្លេ បឹងបួរ និងត្រើយសមុទ្រ) ទ្រព្យដែលត្រូវបានអភិវឌ្ឍជាពិសេសសម្រាប់ការប្រើប្រាស់ទូទៅ (ដូចជា កំពង់ផែ ផ្លូវដែក និងព្រលាន យន្តហោះ) ទ្រព្យសម្រាប់ប្រើប្រាស់ជាសាវាសាធារណៈ (ដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវដើរ និងសួនសាធារណៈ) ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យដំណើរការសម្រាប់សេវាសាធារណៈ (ដូចជា សាលារៀន អគាររដ្ឋបាលនិងមន្ទីរពេទ្យ) តំបន់ការពារតំបន់បេតិកភ័ណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ និងទ្រព្យសម្បត្តិផ្លូវការរបស់ខ្សែព្រះរាជវង្សានុវង្ស។[8]

កម្មសិទ្ធិឯកជនរបស់រដ្ឋ សំដៅរាល់ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរដ្ឋនិងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។ ដីឯកជនរបស់រដ្ឋមានរួម បញ្ចូលដូចជា ទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឲ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់អត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។[9]

### ១.១.៣.២ កម្មសិទ្ធិសមូហភាព

កម្មសិទ្ធិសមូហភាពត្រូវបានចែកចេញជា២ផ្នែកគឺ អចលនវត្ថុរបស់វត្តនិងអចលនវត្ថុរបស់សហគមន៍។ អចលនវត្ថុរបស់វត្តដូចជាដីឬសំណង់ទាំងក្នុង និងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនា រីឯអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិចដូចជា ដីធ្លីនិវេសនដ្ឋានដីដាំដុះជាប្រពៃណីនិងដីដូរវេនដំណាំរបស់សហគមន៍ជនជាតិដើមភាគតិច។[10] កម្មសិទ្ធិសមូហភាពទាំងពីរផ្នែកគឺៈអចលនវត្ថុរបស់វត្តគឺ ជាដីវត្ត កុដិ ព្រះវិហារ និងសាលាឆាន់ដែលអាចស្ថិតនៅក្នុង និងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលជាធម្មតាត្រូវតែមានចុះបញ្ជីទ្រព្យដោយវត្ត ដោយគណៈកម្មាធិការវត្ត និងទទួលស្គាល់ដោយក្រសួងធម្មការនិងសាសនា។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជួយដល់វត្តក្នុងការធ្វើអត្តសញ្ញាណកម្មទ្រព្យកសាងប្លង់សុរិយោដីចេញប័ណ្ណកម្មសិទ្ធិចុះបញ្ជីដីវត្ត និង

[8] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ៧ តុលា ២០០៥, មាត្រា៤ (តទៅហៅថាអនុក្រឹត្យលេខ១១៨)។

[9] អនុក្រឹត្យ១១៨, មាត្រា៥។

[10] ច្បាប់ភូមិបាល២០០១, មាត្រា២០ និងមាត្រា២៥។

ផ្តល់ព័ត៌មានដល់គណៈកម្មាធិការអាចារ្យ និងព្រះចៅអធិការវត្តអំពីក្បាលដីប្រភេទទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗទៀត។ អចលនវត្ថុរបស់វត្តមិនអាចលក់ដូរឬធ្វើអំណោយទៅអ្នកណាម្នាក់បានឡើយ និងគ្មានអាជ្ញាយុកាលទេក៏ប៉ុន្តែអាចយកទៅជួល ឬប្រវាស់បានដើម្បីរកចំណូលទ្រទ្រង់កិច្ចការក្នុងព្រះសាសនា។[11] រីឯអចលនវត្ថុរបស់សមាគមន៍ជនជាតិដើមភាគតិចតាមច្បាប់ភូមិបាល២០០១បានកំណត់ថាដីជនជាតិដើមភាគតិចមានជាអាទ៍ដីសាងសង់និវេសនដ្ឋាន និងដីប្រកបរបរជាប្រពៃណី រួមមានដីកំពុងដាំដុះជាក់ស្តែងនិងដីបម្រុងផ្សេងទៀតសម្រាប់ដំណាំដូរវេន។ ច្បាប់ភូមិបាលបានតម្រូវឲ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើអត្តសញ្ញាណកម្មទ្រព្យកសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិចុះបញ្ជីដីធ្លី និងផ្តល់ព័ត៌មានដល់សហគមន៍ជនជាតិដើម ភាគតិចអំពីក្បាលដីប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗទៀត។ ដីសាធរណៈរបស់ រដ្ឋដែលរដ្ឋចែកឲ្យសមាគមន៍ជនជាតិដើមភាគតិចមិនអាចយកទៅចែកឲ្យបុគ្គល ឬក្រុមណាមួយ បានឡើយ។[12] ប៉ុន្តែ ច្បាប់ភូមិបាលកម្ពុជាផ្តល់សិទ្ធិឲ្យសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ទទួលបានកម្មសិទ្ធិ ឯកជនលើអចលនវត្ថុ តាមរយៈការផ្ទេរអចលនវត្ថុរបស់សហគមន៍ ដែលមិនមែនជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ។ អាចជ្ញាធរមិនអាចទទួលបានសិទ្ធិលើអចលនវត្ថុ របស់សហគមន៍ជនជាតិ ដើម ភាគតិចទេ។[13]

### ១.១.៣.៣ កម្មសិទ្ធិឯកជន

ប្រជាពលរដ្ឋគ្រប់រូបដែលមានប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុគឺ ជាម្ចាស់កម្មសិទ្ធិពេញលេញតាមផ្លូវច្បាប់ (ឬហៅថាកម្មសិទ្ធិករ)។ កម្មសិទ្ធករមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខនិងទូលំទូលាយ លើកលែងតែកម្មសិទ្ធិករប្រើប្រាស់ទ្រព្យដើម្បីព្យាបាទ ឬរំខានតតិយជន និងអ្នកជិតខាង ប៉ុន្តែការប្រើប្រាស់ទ្រព្យមានចរិកជាធម្មានុរូប មិនចាត់ទុកជាការរំខានទេ។[14] ប្រភេទនៃកម្មសិទ្ធិឯកជនមានដូចជាៈកម្មសិទ្ធិអវិភាគ គឺជាកម្មសិទ្ធិលើទ្រព្យតែមួយដែលជារបស់បុគ្គលច្រើនអ្នកដោយម្នាក់ៗមានចំណែករបស់ខ្លួនក្នុងទ្រព្យមួយ ដែលមិនអាចពុះចែកគ្នាបាន។បុគ្គលទាំងនោះត្រូវបានគេហៅថាកម្មសិទ្ធិករអវិភាគ។ ការជួសជុលធំៗ ឬប្តូរដំណាំ ត្រូវផ្អែកលើការយល់ព្រមដោយកម្មសិទ្ធិករអវិភាគ ដែលមានចំណែករួមគ្នាច្រើនជាងពាក់កណ្តាល

[11] ច្បាប់ភូមិបាល២០០១, មាត្រា២១។
[12] ច្បាប់ភូមិបាល២០០១, មាត្រា២៦។
[13] ច្បាប់ភូមិបាល២០០១, មាត្រា២៨។
[14] ច្បាប់ភូមិបាល២០០១, មាត្រា៨៥ និងមាត្រា៨៦។

ប៉ុន្តែការបង់ថ្លៃភ្លើង និងទឹកជាដើមត្រូវផ្អែកតាមសមាមាត្រ។[15] កម្មសិទ្ធិអវិភាគនឹងចប់ ដោយការបែងចែកទ្រព្យតាមរូបដើម ឬដោយការលក់ទ្រព្យហើយចែកថ្លៃគ្នា ឬដោយកម្មសិទ្ធិករអវិភាគម្នាក់ ឬច្រើនអ្នកទទួលយកចំណែករបស់អ្នកដទៃ។[16] ចំណែកអឌ្ឍសិទ្ធិភាព ជាស្ថានភាពដែលជនដែលមានកម្មសិទ្ធិលើដីជាប់គ្នាមានកម្មសិទ្ធិរួមដោយ មានភាពអវិភាគលើជញ្ជាំង ឬកំពែងដូចជាស្នាមភ្លោះ ភ្លឺ របង ជាអាទ៍ ដែលនៅត្រង់ព្រំ ខណ្ឌ ដី ឬអគារលើដីនោះ។[17] រីឯសហកម្មសិទ្ធិ គឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់បែងចែកតាមឡូត៍ដែលម្នាក់ៗ បានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។ ចំណែកផ្ដាច់មុខរបស់សហកម្មសិទ្ធិករ គឺជាចំណែកឯកជន ចំពោះផ្នែកដែលប្រើរួមដោយសហកម្មសិទ្ធិករគឺជាចំណែករួម មានដី ទីធ្លាឧទ្យាន និងសួនច្បារ ផ្លូវច្រកចេញចូល ជញ្ជាំង សសរទ្រទ្រង់ សំខាន់ៗនៃអគារ បណ្ដាញឧស្ម័នដែលអាចឆ្លងកាត់ចំណែកឯកជន ទូរួម បំពង់ និងក្បាលបំពង់ ផ្សែង ទីកន្លែងនៃសេវារួម។[18]

## ១.២ ប្រវត្តិនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា

នៅឆ្នាំ១៩៨៩រដ្ឋបានសម្រេចផ្ដល់កម្មសិទ្ធិឯកជនលើដីធ្លីដល់ប្រជាពលរដ្ឋ។ មេគ្រួសារដែលបានកាន់កាប់ដីធ្លីត្រូវដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លីមកគណៈកម្មាធិការប្រជាជនស្រុក តាមរយៈឃុំដែលកំពុងរស់នៅតាមគម្រូបែបបទដែលក្រសួងកសិកម្មបោះពុម្ពចែកជូន។[19] រដ្ឋបានកំណត់ទំហំដី សម្រាប់ការកាន់កាប់ ដោយកំណត់ដីលំនៅដ្ឋានមានទំហំត្រឹមតែ២.០០០ម$^{២}$និងដីផលិតកម្ម កសិកម្មមិនឲ្យលើសពី៥ហិចតា។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់ភូមិបាលថ្មីមួយ គឺច្បាប់ភូមិបាលឆ្នាំ១៩៩២។ តាមរយៈច្បាប់នេះកម្មសិទ្ធិដីធ្លីឯកជននៅមានលក្ខណៈចង្អៀតចង្អល់នៅឡើយ កម្មវត្ថុតែមួយគត់នៃកម្មសិទ្ធិដីធ្លីឯកជនគឺដីលំនៅដ្ឋាន។[20] ច្បាប់ភូមិបាលបានបង្កើតឲ្យមានការចុះបញ្ជីកម្មសិទ្ធិ ការចុះបញ្ជីភោគៈ និងការចុះចរន្តការផ្ទេរ ឬបំបែកក្បាលដីជាដើម ការចុះបញ្ជីនេះត្រូវកត់ត្រាចូលសៀវភៅពីរផ្សេងគ្នា ចំពោះកម្មសិទ្ធិត្រូវចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុរីឯភោគៈត្រូវចុះក្នុងសៀវភៅចុះភោគៈអចលនវត្ថុ។ រាល់ការធ្វើចរន្តការក៏ត្រូវចុះទៅតាម ប្រភេទ

[15] ច្បាប់ភូមិបាល២០០១, មាត្រា១៧០ និងមាត្រា១៧២។
[16] ច្បាប់ភូមិបាល២០០១, មាត្រា១៧៤។
[17] ក្រមរដ្ឋប្បវេណី២០០៧, មាត្រា២១៥។
[18] ច្បាប់ភូមិបាល២០០១, មាត្រា១៧៥ និងមាត្រា១៧៩។
[19] សេចក្ដីណែនាំស្ដីពីការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩, ចំណុចទី២ (តទៅហៅថា សេចក្ដីណែនាំលេខ០៣)។
[20] ច្បាប់ភូមិបាល១៩៩២, មាត្រា១៩។

កម្មសិទ្ធិ និងភោគៈដែរ ពោលគឺការធ្វើចរន្តការផ្ទេរកម្មសិទ្ធិត្រូវចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ហើយការផ្ទេរភោគៈត្រូវកត់ត្រាចូលសៀវភៅចុះភោគៈអចលនវត្ថុ។[21]

លុះដល់ឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសហប្រតិបត្តិការបច្ចេកទេសទ្វេភាគីជាមួយបណ្តាប្រទេសជឿនលឿនមួយចំនួនសំដៅ បញ្ចូលបណ្តើរៗ នូវបច្ចេកទេសទំនើបលើការកសាងប្លង់សុរិយោដីក្នុងការចុះបញ្ជីដីធ្លី លើការកាន់កាប់ទុកដាក់ឯកសារសុរិយោដី និងជាពិសេសការគ្រប់គ្រងប្រព័ន្ធទិន្នន័យ (Database Managerment System) ទាក់ទងនឹងដីធ្លី។ បណ្តាប្រទេសសហប្រតិបត្តិការទាំងនេះមានដូចជា ប្រទេសអាល្លឺម៉ង់[22] តាមគ្រោងគ្រប់គ្រងដីធ្លី (Land Management Project) អនុវត្តដោយនាយកដ្ឋានសុរិយោដី និងអង្គការ GTZ នៅខេត្ត កណ្តាល កំពង់ធំ និងតាកែវ ប្រទេសហ្វាំងឡង់[23] តាមគម្រោង សុរិយោដីកម្ពុជា (Cambodian Cadastral Project) អនុវត្តដោយ នាយកដ្ឋានសុរិយោដី និងអង្គការFINNMAP នៅ ខេត្តតាកែវ និងប្រជាមួយប្រទេសបារាំង[24] តាមគ្រោង កសាងផែនទី (Cadastral Mapping Project) អនុវត្តដោយ មន្ទីរសុរិយោដីភ្នំពេញ និងអង្គការ IGN.FI នៅរាជធានីភ្នំពេញ។[25]

នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ច្បាប់ភូមិបាលថ្មីត្រូវបានប្រកាសឲ្យប្រើ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនៃការអភិវឌ្ឍរបស់សង្គម។ ច្បាប់ភូមិបាលឆ្នាំ២០០១ បាន បញ្ញត្តបង្កើតឲ្យមានការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និង ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំត្រូវផ្អែកតាមអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងសារាចរណែនាំលេខ១៤ ដនស/សរណន ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំចុះ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ រីឯការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធផ្អែកតាម អនុក្រឹត្យ លេខ៤៦ អនក្រ.បក ចុះថ្ងៃ៣១ ខែ ឧសភាឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងសារាចរ ណែនាំលេខ០០១ ដនស/សដ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការអនុវត្តនីតិវិធីនៃការកសាង ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ សរុបការអនុវត្តពីពេលចាប់ផ្តើមអនុវត្តរហូតដល់ខែធ្នូ ឆ្នាំ

---

[21]ច្បាប់ភូមិបាលឆ្នាំ១៩៩២, មាត្រា២០៥ ដល់មាត្រា២០៨។

[22] ប្រទេសអាល្លឺម៉ង់សហការចុះបញ្ជីនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៩៤។

[23] ប្រទេសហ្វាំងឡង់សហការចុះបញ្ជីនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៦។

[24] ប្រទេសបារាំងសហការចុះបញ្ជីនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦។

[25] ហាប់ផល្ធី, បញ្ហានានាពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា(១២.៧.២០១០), ២, phalthy.files.wordpress.com (ចូលទស្សនាថ្ងៃទី ១០ កក្កដា ២០១៩)

២០១៨ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ៦១៥ ៨៧៦ប័ណ្ណ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន ៩.៥២២.៩៤៣ប័ណ្ណ។[26]

[26] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

# ជំពូកទី២

# ការអនុវត្តចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល

## ២.១ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ បានចាប់ផ្តើមពីឆ្នាំ១៩៨៩តាមរយៈការប្រកាសឲ្យដាក់ពាក្យសុំកាន់កាប់ដី នៅថ្ងៃទី០៣ ខែមិថុនាឆ្នាំ១៩៨៩ ដល់ថ្ងៃទី៣១ ខែធ្នូឆ្នាំ១៩៩០។[27] ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ គឺជាការចុះបញ្ជីនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រ កម្ពុជាក្នុងតំបន់ដែលមិនទាន់ បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ជាមួយការស្នើសុំទៅកាន់ រដ្ឋបាលសុរិយោដី ស្រុក ខណ្ឌតាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីនោះស្ថិតនៅ។

បន្ទាប់ពីរដ្ឋបាលសុរិយោដីបានពិនិត្យលើពាក្យសុំ មានលក្ខណៈគ្រប់គ្រាន់ និងសមស្របតាមការកំណត់ហើយនោះ រដ្ឋបាលសុរិយោដី ស្រុក ខណ្ឌនឹងកត់ត្រាចូលសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទចុះធ្វើការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ។

### ២.១.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ផ្អែកតាមសារាចរណែនាំលេខ១៤ ស្តីពីការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ ដោយដុំ ការចុះបញ្ជីដីធ្លីដាច់ដោយដុំ ត្រូវធ្វើឡើងជា៥ដំណាក់កាលគឺ ការដាក់ពាក្យស្នើសុំ (២.១.១.១) កិច្ចប្រតិបត្តិការបច្ចេកទេស (២.១.១.២) ការបិទផ្សាយជាសាធារណៈ (២.១.១.៣) ការសម្រេចលើឯកសារ (២.១.១.៤) និងការចេញប័ណ្ណ (២.១.១.៥)។

#### ២.១.១.១ ការដាក់ពាក្យស្នើសុំ

ដើម្បីអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនេះ ជាដំបូងគឺត្រូវមានការដាក់ពាក្យស្នើសុំពីអ្នកកាន់កាប់ដីធ្លីនោះ។ សាមីជាអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដែលបានកំណត់មករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។[28] ពាក្យស្នើសុំត្រូវមាន ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ឯកសារ និងភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី។

---

[27] ហាប់ ផល្លី, "នីតិទ្រព្យសម្បត្តិ", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៣នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៥)។

[28] អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្របក, ៣១ ឧសភា ២០០២, មាត្រា៧ (តទៅហៅថាអនុក្រឹត្យលេខ៤៨)។

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឲ្យសាមីអ្នកកាន់កាប់ដីបំពេញបាន គ្រប់គ្រាន់តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្តីដែលសាមីអ្នកស្នើសុំបានបំពេញនោះស្រប តាមហេតុការណ៍ដែលបានកើតឡើងជាក់ស្តែងដែរឬទេ? ចំណុចដែលត្រូវយកចិត្ត ទុកដាក់ជាសំខាន់នោះគឺលក្ខណៈនៃការចូលកាន់កាប់ដីមានប្រើអំពើហិង្សា ឬគ្មាន? កាលបរិច្ឆេទនៃការចូលកាន់កាប់ដីពិតប្រាកដដែរឬទេ? ទីតាំងក្បាលដីមានប៉ះពាល់ដល់ទ្រព្យសាធារណៈរដ្ឋដែរឬទេ? ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជីមានទំនាស់ដែរឬទេ? បន្ទាប់ពិនិត្យឃើញថាពាក្យស្នើសុំមាន លក្ខណៈគ្រប់គ្រាន់ហើយ មេឃុំ ឬចៅសង្កាត់នោះត្រូវចារលើពាក្យស្នើសុំទាំងនោះមករដ្ឋបាល សុរិយោដីស្រុក ខណ្ឌ ក្រុង។[29] បន្ទាប់ពីរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌទទួលពក្យស្នើសុំពីមេឃុំ ឬចៅសង្កាត់រួចមក រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវពិនិត្យពាក្យស្នើសុំ ចុះបញ្ជីដោយផ្អែកលើគោលការជំនាញ និងច្បាប់។[30]ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវកត់ត្រាចូលសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។ ចំពោះករណីពីនិត្យឃើញថា ពាក្យសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចារលើពាក្យដោយបញ្ជាក់មូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបានហើយ អ្នកដាក់ពាក្យមានសិទ្ធិប្តឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង។ ករណីមានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌតាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី។[31]

អភិបាលក្រុង ស្រុក ខណ្ឌត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការ កំណត់ព្រំដីទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃយ៉ាងតិចមុនកាលបរិច្ឆេទនៃការកំណត់ព្រំដី នៅសាលាក្រុង ស្រុក ខណ្ឌ សាលាសង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។[32]

[29] សារាចរណែនាំស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ០១៤ដនស/សរណន,៣០ កញ្ញា ២០០៩, ដំណាក់កាលទី១ កថាខណ្ឌទី២ (តទៅហៅថាសារាចរណែនាំលេខ០១៤)។

[30] សារាចរណែនាំលេខ០១៤, ដំណាក់កាលទី១ កថាខណ្ឌទី៣។

[31] អនុក្រឹត្យលេខ៤៨, មាត្រា៨។

[32] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ/បក,៩ មិថុនា ២០១៦, មាត្រា៩ (តទៅហៅថាអនុក្រឹត្យលេខ១២១)។

### ២.១.១.១ កិច្ចប្រតិបត្តិការបច្ចេកទេស

នៅក្នុងដំណាក់កាលនេះត្រូវអនុវត្តជាពីរជំហាន គឺជំហានទី១ ការអនុវត្តដោយមន្ត្រីជំនាញ ដោយមានការសហការជាមួយអាជ្ញាធរមូលដ្ឋាននូវក្បាលដីដែលបានដាក់ពាក្យសុំចុះបញ្ជី ហៅថាការងារវាល (ក) ជំហានទី២ គឺការយកទិន្នន័យដែលបានមកពីជំហានទី១ទៅចងក្រង និងបញ្ចូលទៅក្នុងកុំព្យូទ័រហៅថាការងារការិយាល័យ (ខ)។

ក.ការងារវាល

យោងតាមការណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំជាក់ស្តែងរបស់ថ្នាក់ដឹកនាំរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ តាមរយៈភូមិសាស្ត្រដោយឡែក។ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីជំនាញ ដោយមានការសហការ និងការជួយជ្រោមជ្រែងពី មន្ត្រីមូលដ្ឋាន (មេភូមិ មេឃុំ និងចៅសង្កាត់) មន្ត្រីជំនាញដែលត្រូវចាត់តាំងឲ្យទទួលបន្ទុកការងារ វាល មានភារកិច្ចទទួលខុសត្រូវ លើការកំណត់ព្រំដែន ការវាស់វែង ការងារបំពេញទម្រង់បែបបទ នៃការប្រមូលទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យ ឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោល ការណ៍ច្បាប់។ ប្រសិនបើរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ណាមួយមិនអាចបំពេញភារកិច្ចតាមលក្ខខណ្ឌដើម្បីធ្វើការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីបានទេក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួនដោយ ការខ្វះមន្ត្រី ឬភាពខ្វះខាតនូវសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីនោះអាចស្នើសុំឲ្យរដ្ឋបាល សុរិយោដីរាជធានីខេត្តជួយដល់ការអនុវត្តនូវការងារទាំងអស់នោះបាន។[33]

ការកំណត់ព្រំ ដូចដែលបានលើកឡើងពីខាងលើ រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌជាអ្នកលើកសំណើ កំណត់អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវអនុវត្ត ក្រោយមកស្រុក ក្រុង ខណ្ឌត្រូវធ្វើសេចក្តីជូនដំណឹង អំពីកាលបរិច្ឆេទ និងទីកន្លែងត្រូវអនុវត្ត។ យោងតាមសេចក្តី ជូនដំណឹងនេះ មន្ត្រីកំណត់ព្រំដីត្រូវ ចុះប្រតិបត្តិការតាមពេលវេលា និងទីកន្លែងដែលត្រូវបាន កំណត់នោះ។ មន្ត្រីទទួល បន្ទុកកំណត់ព្រំដីមានសិទ្ធិចូលក្នុងបរិវេណដី ដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជន ដែលពាក់ព័ន្ធឲ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឯកសារ និងបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីនោះ។[34]នៅក្នុងភារកិច្ចកំណត់ព្រំ មន្ត្រីទទួលបន្ទុកកំណត់ ព្រំត្រូវអនុវត្តតាមគោលការណ៍ដូចជា៖ ១.កំណត់ព្រំដោយផ្អែកលើការព្រមព្រៀងរវាងភាគីជាប់ព្រំ ២.ករណីអវត្តមានភាគីការកំណត់ត្រូវផ្អែកលើភស្តុតាង ដែលជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់

[33] សារាចរណែនាំលេខ១៤, ដំណាក់កាលទី២ កថាខណ្ឌ១ និងកថាខណ្ឌ២។

[34] សារាចរណែនាំលេខ១៤, ដំណាក់កាលទី២ ចំណុច១.១ (ក)។

ដែលទាក់ទងនឹងព្រំដីនោះ ៣.ករណីដីដែលស្នើសុំចុះបញ្ជីស្ថិតនៅ ជាប់នឹងដី សាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈការកំណត់ព្រំដីត្រូវធ្វើតាមចំណុច២ ខាងលើ។ វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដីត្រូវបានបញ្ជូនទៅធ្វើ ការសម្រុះសម្រួលនៅថ្នាក់ក្រុងស្រុក ខណ្ឌតាមនីតិវិធីដែលបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី។[35]

ចំពោះការវាស់វែងត្រូវបានចាប់ផ្តើមអនុវត្ត បន្ទាប់ពីមានការកំណត់ព្រំត្រូវបានបញ្ចប់ជាស្ថាពរការវាស់វែង គឺជាប្រតិបត្តិការបច្ចេកទេសមួយ ក្នុងគោលបំណងទៅតាមតម្រូវការនៃការកសាងផែនទី ក្បាលដី (Parcel Map) គំនូសបង្ហាញទីតាំងក្បាលដី និងផែនទីលក្ខណៈដាច់ដោយដុំក្នុងតំបន់នីមួយៗ។ក្នុងប្រព័ន្ធនេះការវាស់វែងអាចប្រព្រឹត្តទៅបាន តាមវិធីពីរអាស្រ័យទៅលើលក្ខណៈនៃភូមិសាស្ត្រ និងឧបករណ៍វាស់វែង។[36]

អំពីការវិនិច្ឆ័យមន្ត្រីទទួលបន្ទុកវិនិច្ឆ័យមានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យអាច អញ្ជើញជនពាក់ព័ន្ធឲ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឯកសារ និងវត្ថុតាងផ្សេងៗដែលទាក់ទងនឹងការវិនិច្ឆ័យ។ មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវកត់ត្រាព័ត៌មានអំពីម្ចាស់ដី ក្បាលដីព្រមទាំងសិទ្ធិ និងបន្ទុកទាំងអស់ដែលមានលើក្បាលដី ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឲ្យអ្នកជាប់ពាក់ព័ន្ធទាំងអស់មកផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យនោះ ក៏ត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ។ បន្ទាប់មកទម្រង់បែបបទនេះ ក៏ត្រូវដាក់ជូនរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាបញ្ជាក់។ ក្នុងករណីមានវិវាទកើតឡើងទាក់ទងនឹងព្រំប្រទល់ក្បាលដីក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តីមន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យត្រូវកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យថា "ជាដីមានទំនាស់" និងបញ្ជាក់អំពីប្រភេទនៃដីទំនាស់នោះផង។[37] ចំពោះដីភោគៈការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ពីរគឺទី១ដីដែលបានចុះបញ្ជីត្រូវបានកាន់កាប់ មុនថ្ងៃទី៣០ខែសីហាឆ្នាំ២០០១ រីឯទី២ ដីដែលស្នើសុំចុះបញ្ជីត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់។[38]

សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់៖ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការងារកំណត់ព្រំដី វាស់

[35] អនុក្រឹត្យលេខ៤៨, មាត្រា១០ (២)។

[36] សារាចរណែនាំលេខ១៤, ដំណាក់កាលទី២ ចំណុច១.១ (ខ)។

[37] សារាចរណែនាំលេខ១៤, ដំណាក់កាលទី២ ចំណុច១.១ (គ)។

[38] អនុក្រឹត្យស្តីលេខ៤៨, មាត្រា១១។

វែង និងវិនិច្ឆ័យដោយផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ជាលាយលក្ខណ៍ អក្សរ ឬភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនត្រូវបានចាត់ធ្វើជា តំណាង ឬក្បាលដីអ្នកជាប់ព្រំ ជូនមន្ត្រីជំនាញ។ ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញអ្នកកាន់កាប់ដី ឬអ្នកតំណាង ស្រប ច្បាប់របស់ជននេះ ឬជនមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិជំទាស់ ឬតវ៉ាប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យ ឬឯកសារផ្សេង ទៀតទាក់ទងនឹងការវិនិច្ឆ័យនោះ មិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន។[39]

ភារកិច្ចអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបង្កលក្ខណៈងាយស្រួលសហការឲ្យបានល្អ និង ផ្តល់សុវត្ថិភាពណដល់កិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញដើម្បីធ្វើឲ្យសម្រេចនូវការអនុវត្តនីតិវិធីនៃ ការវិនិច្ឆ័យ។ ក្នុងករណីចាំបាច់រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកម្លាំងប្រដាប់ អាវុធឲ្យជួយជ្រោមជ្រែងដល់ការអនុវត្តការងារវាល។[40] ក្នុងការផ្តល់យោបល់លើពាក្យស្នើសុំ ឬឯក សារ ព័ត៌មានពាក់ព័ន្ធនឹងការកំណត់សិទ្ធិលើដី ពិសេសការផ្តល់ទាក់ទងនឹងលក្ខខ័ណ្ឌនៃការកាន់ កាប់ដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ដី ត្រូវតែជាព័ត៌មានពិត មិនបំភ្លៃ បំភាន់ ឬផ្អែកលើ មនោសញ្ចេតនាបុគ្គល ដែលជាហេតុនាំឲ្យការកំណាត់សិទ្ធិលើអចលនវត្ថុមិនបានត្រឹមត្រូវនឹងនាំឲ្យ កើតមានទំនាស់។[41] ក្នុងរយៈពេលនៃការបិទផ្សាយនូវឯកសារវិនិច្ឆ័យក្នុងឃុំ ឬសង្កាត់ណា មេឃុំ ឬ ចៅសង្កាត់នោះត្រូវមានវត្តមានតាមតម្រូវការជាក់ស្តែងនៃការងារ។[42]

ខ.ការងារការិយាល័យ

រាល់ឯកសារទាំងឡាយដែលទទួលបានពីការងារវាលត្រូវបានយកមកធ្វើជាការគ្រប់គ្រង និងកសាងផែនទី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជី។ នៅក្នុងនីតិវិធីនៃការចុះបញ្ជីដីមាន លក្ខណៈដាច់ដោយដុំ ខុសគ្នាមួយចំនួនពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ពោលគឺទិន្នន័យ ដែលទទួលបានពីការងារវាលមានគុណភាពពីរបែបគឺ ទី១អាច បញ្ចូលក្នុងកុំព្យូទ័រដើម្បីកសាង ផែនទីក្បាលដី ផែនទីបង្ហាញពីទីតាំងក្បាលដីស្នើសុំផែនទីមានលក្ខណៈដាច់ដោយដុំកសាងបញ្ជី ចុះឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុចំពោះក្បាលដី ដែលត្រូវវាស់វែងដោយឧបករណ៍ ទំនើប។ ទី២គឺអាចគូរផែនទីក្បាលដី គូរគំនូសបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់

[39] សារាចរណែនាំលេខ០១៩, ដំណាក់កាលទី២ ចំណុច១.២។

[40] សារាចរណែនាំលេខ០១៩, ដំណាក់កាលទី២ ចំណុច១.៣។

[41] សារាចរណែនាំលេខ០១៩, ដំណាក់កាលទី២ ចំណុច១.៣។

[42] ប្រកាសអន្តរក្រសួងស្តីពីតួនាទី និងការទទួលខុសត្រូវរដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី, លេខ២១៥ប្រក/ដនស/មផ, ៩ កញ្ញា ២០០៥, មាត្រា៣។

ដោយដុំកសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុចំពោះក្បាលដីដែលការវាស់វែងត្រូវបានធ្វើឡើងដោយឧបករណ៍សាមញ្ញ។ របៀបរៀបចំខ្លឹមសារ និងការកាន់កាប់ឯកសារសុរិយោដីៈ សៀវភៅគោលបញ្ជីដីធ្លីសៀវភៅចុះបញ្ជីដីធ្លីអចលនវត្ថុ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបញ្ជីឈ្មោះម្ចាស់ដីផែនទីក្បាលដីផែនទីមានលក្ខណៈដាច់ដោយដុំ និងឯកសារណាបផ្សេងៗទៀតត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។[43]

### ២.១.១.៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ គឺជាប្រការយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានដល់សាធារណៈជនដែលមានផលប្រយោជន៍ពាក់ព័ន្ធលើកម្មសិទ្ធិដី ចូលរួមពិនិត្យ និងបញ្ជាក់ ពីភាពត្រឹមត្រូវលើក្បាលដីនោះ ហើយអាចតវ៉ាបានភ្លាមៗ។ បន្ទាប់ពីការពិនិត្យច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។ ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយរួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យត្រូវធ្វើឡើងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ នៅសាលាក្រុង ស្រុក ខណ្ឌ ដែលមានសមត្ថកិច្ច។ សេចក្តីចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរនៅទីស្នាក់ការឃុំ សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។

អភិបាលក្រុង ស្រុក ខណ្ឌមានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយឯកសារក្នុងការវិនិច្ឆ័យដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្តីជូនដំណឹងនេះត្រូវធ្វើឡើងយ៉ាងតិច៣ (បី) ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញនៅ ក្នុងភូមិនៅសាលាឃុំ សង្កាត់ និងនៅសាលសាក្រុង ស្រុក ខណ្ឌ។[44]

ក្នុងរយៈពេលនៃការបិទផ្សាយ សាមីអ្នកកាន់កាប់ ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងពីការជំទាស់របស់ខ្លួន ឬធ្វើបណ្តឹងជំទាស់ ឬបណាញតឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់អ្នកប្រចាំការនៅកន្លែងបិទផ្សាយ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុងត្រូវធ្វើការស៊ើបអង្កេតលើការជំទាស់នោះដោយផ្អែកតាមឯកសារ និងព័ត៌មានទាំងអស់ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី។

[43] សារាចរណែនាំលេខ០១៤, ដំណាក់កាលទី២ ចំណុច២។

[44] អនុក្រឹត្យស្តីលេខ១២១, មាត្រា១៣។

ករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈសមហេតុផលរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ អាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ។ ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យអាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

ករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈមិនសមហេតុផល និងដោះស្រាយតាមនីតិវិធីដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។ បណ្តឹងនីមួយៗត្រូវធ្វើកំណត់ត្រាដោយឡែក ហើយត្រូវបញ្ជាក់អំពីកម្មវត្ថុនៃបណ្តឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីកត់ត្រា និងមានការបញ្ជាក់ដឹងឮពីមេឃុំ ចៅសង្កាត់ ឬតំណាង។ ក្នុងករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យក ជាផ្លូវការតាមច្បាប់បាន។[45]

### ២.១.១.៤ ការសម្រេចលើឯកសារ

ក្រោយពីផុតរយៈពេលនៃការបរិច្ឆេទបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ តាមខ្លឹមសារដូចជាៈលទ្ធផលសម្រេចបាន មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើការវាយតម្លៃលើកសំណើផ្តល់សិទ្ធិលើដីឬអចលនវត្ថុជូនអ្នកកាន់កាប់ដែលបានស្នើសុំ និងត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ។[46]

ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីត្រូវបានកែតម្រូវរួចហើយមន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំ ត្រូវរៀបចំឯកសារ ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ពិនិត្យ និងបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត។[47] រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុងដូចជាៈ ពាក្យស្នើសុំចុះបញ្ជី ឯកសារនៃការវិនិច្ឆ័យ សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន

[45] សារាចរណែនាំលេខ១៩, ដំណាក់កាលទី៣។

[46] សារាចរណែនាំលេខ១៩, ដំណាក់កាលទី៤ ចំណុចទី១។

[47] សារាចរណែនាំលេខ១៩, ដំណាក់កាលទី៤ ចំណុចទី២។

លិខិតស្នើសុំកែតម្រូវប្រសិនបើមាន និងកំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយ ក្នុងករណីដែលពិនិត្យឃើញថាឯកសារទាំងអស់នោះគ្រប់គ្រាន់ នឹងត្រឹមត្រូវហើយរដ្ឋបាល សុរិយោដីខេត្ត ក្រុងត្រូវហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល។[48]

### ២.១.១.៥ ការចេញប័ណ្ណ

បន្ទាប់ពីបានទទួលសំណុំរឿងពីរដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ រដ្ឋបាលសុរិយោដីរាជធានីខេត្តត្រូវះ ពិនិត្យ និងផ្ដល់យោបល់ជូនអភិបាលរាជធានីខេត្តសម្រេចយល់ព្រមឲ្យចេញប័ណ្ណ ឬជំទាស់ត្រង់ចំណុចណា ឬច្រានចោលទាំងស្រុងតែម្ដង។ ករណីអភិបាល រាជធានី ខេត្តជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោល អភិបាលរាជធានី ខេត្តនោះត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ពីមូលហេតុនៃការជំទាស់ ឬការច្រានចោលនោះ ដើម្បីរដ្ឋបាលសុរិយោដីជម្រាបទៅអ្នកស្នើសុំឲ្យបានជ្រាប។ ពិនិត្យ និងផ្ដល់យោបល់ជូនអភិបាលរាជធានី ខេត្ត សម្រេចយល់ព្រម ឬជំទាស់ ត្រង់ចំណុចណាមួយ ឬច្រានចោលមិនផ្ដល់ប័ណ្ណជូនអ្នកស្នើសុំ។ ករណីអភិបាល រាជធានីខេត្ត សម្រេចយល់ព្រម រដ្ឋបាលសុរិយោដីរាជធានី ខេត្តដែលមិនទាន់បានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាលត្រូវបញ្ជូនសំណុំរឿងនេះបន្តមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដើម្បីពិនិត្យ បន្ថែមតាមគោលការណ៍ជំនាញ បើឃើញថាត្រឹមត្រូវ ត្រូវធ្វើការចុះបញ្ជីហើយចេញប័ណ្ណជូនអ្នកស្នើសុំ។ តែបើមានចំណុចណា មិនទាន់ត្រឹមត្រូវ ឬមិនគ្រប់គ្រាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវណែនាំរដ្ឋបាល សុរិយោដី រាជធានី ខេត្ត កែតម្រូវ ឬបំពេញឡើងវិញដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ជាមូលដ្ឋាន។ ករណីអភិបាលរាជធានី ខេត្តជំទាស់ចំណុចណាមួយ ឬច្រានចោលទាំង ស្រុងតែម្ដងរដ្ឋបាលសុរិយោដីរាជធានី ខេត្តត្រូវពិនិត្យមើលចំណុចនោះឡើងវិញ ហើយរាយការណ៍សុំយោបល់ អភិបាលរាជធានី ខេត្ត ជាលើកទី២ ប្រសិនបើពិនិត្យឃើញថាមូលហេតុនៃការជំទាស់ ឬច្រានចោលនោះ មិនសមស្របនឹងសភាពការណ៍ពិតដូចដែលគាត់បានដឹង។ ករណីអភិបាលរាជធានី ខេត្តនៅតែរក្សាការសម្រេចលើកទីមួយរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងនោះមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដោយភ្ជាប់យោបល់ជំទាស់ ឬច្រានចោល និងរបាយការណ៍ពិនិត្យឡើងវិញមកជាមួយដើម្បីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រពិនិត្យ និងសម្រេច។[49]

[48] អនុក្រឹត្យលេខ៤៨, មាត្រា១៦។

[49] សារាចរណែនាំលេខ១៩, ដំណាក់កាលទី៥។

គោលការណ៍នៃការចេញប័ណ្ណដល់អ្នកស្នើសុំចុះបញ្ជីត្រូវអនុវត្តទៅតាមដំណាក់កាលដូចខាងក្រោម៖

១. សមត្ថកិច្ចក្នុងការសម្រេចលើទម្រង់បែបទនៃការប្រមូលទិន្នន័យក្បាលដី និងការចេញប័ណ្ណដីត្រូវបានប្រគល់សិទ្ធិជូនរដ្ឋបាលសុរិយោដីរាជធានីខេត្ត។ ឯសមត្ថកិច្ចក្នុងការវាស់វែងគឺអាស្រ័យទៅលើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ដែល មាន

២.ចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលរួមកាន់កាប់ដីមុនថ្ងៃទី៣០ខែសីហាឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់

៣.ចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ)ជូន ចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬកាន់កាប់បន្តពីភោគីដើម មាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយមានរយៈពេលយ៉ាងតិចជាង៥ឆ្នាំ

៤.អាចចេញប័ណ្ណជូនបាន ចំពោះតែក្បាលដីណាដែលគ្មានទាក់ទិននឹងវិវាទ ឬមានវិវាទតែត្រូវបានដោះស្រាយចប់ជាស្ថាពរ

៥.មិនអាចចេញប័ណ្ណជូនបានទេ ចំពោះក្បាលដីដែលអ្នកស្នើសុំបានចូលកាន់កាប់ដីក្រោយច្បាប់ភូមិបាលចូលជាធរមាន

៦.មិនអាចចេញប័ណ្ណជូនជាឯកជនបានទេ ចំពោះក្បាលដីណាដែលត្រូវបានកំណត់ទាំងស្រុងជាទ្រព្យសម្បត្តិសាធារណៈឬទុកបម្រើសេវាសាធារណៈ។ចំពោះក្បាលដីស្នើសុំចុះបញ្ជីដែលមានចំណែកណាមួយត្រួតគ្នាលើដីដែលជាសម្បត្តិសាធារណៈ ឬទុកបម្រើសេវា សាធារណៈអាចចេញប័ណ្ណជូនបុគ្គលឯកជនបានលុះត្រាតែចំណែកត្រួតគ្នានោះត្រូវបានដកចេញពីទំហំសរុប នៃក្បាលដី

៧.នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដីត្រូវប្រគល់ឯកសារទាំងអស់ទាក់ទងនឹងសិទ្ធិលើក្បាលដីនោះដែលខ្លួនមានពីមុនមកជូនមន្ត្រីសុរិយោដី។ រាល់ឯកសារទាក់ទងនឹងសិទ្ធិលើក្បាលដីដែលសាមីម្ចាស់ដីមិនបានប្រគល់ឬមិនបានរាយការណ៍ពីការប្រើប្រាស់ជូនមន្ត្រីជំនាញមានសមត្ថកិច្ច ត្រូវបានចាត់ទុកជាមោឃៈ និងមិនមានអានុភាពតាមផ្លូវច្បាប់

៨.ការប្រគល់ប័ណ្ណដី ត្រូវបានធ្វើឡើងដោយមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួល ទុកជាភស្តុតាងផង

៩.ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព ឬនាមករណី (នីតិបុគ្គលសាធារណៈ មាន ជាអាទិ៍ សាលារៀន សាលាឃុំ... នីតិបុគ្គលឯកជន មានជាអាទិ៍ សមាគម ក្រុមហ៊ុន...) គឺមិនត្រូវចុះ ឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដី ឬអចលនវត្ថុរបស់សម្ភូហភាព ដូចជាវត្ត ឬ

សហាគមន៍ ជនជាតិដើមភាគតិច.. នៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះ វត្ត ឬសហគមន៍ ...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។[50]

ក.តម្លៃសេវាសាធារណៈនៃការចុះបញ្ជី

តម្លៃសេវាសុរិយោដីដែលបានកំណត់ មានតម្លៃសមរម្យទៅនឹងជីវភាពរបស់ប្រជាពលរដ្ឋ។ ដីក្នុង រាជធានីភ្នំពេញ ឬក្នុងក្រុងរបស់ខេត្តកណ្ដាល ព្រះសីហានុ និងសៀមរាបមានតម្លៃត្រឹមតែ ៤០០.០០០រៀល ប៉ុណ្ណោះក្នុង១ក្បាលដី។ យោងតាមប្រកាសរួមស្ដីពី ការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តម្លៃសេវាសាធារណៈនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានកំណត់ដូចនៅក្នុងតារាងខាងក្រោមៈ

តារាង១៖ តម្លៃសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ[51]

| ២.សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | |
|---|---|---|---|---|---|
| ការចុះបញ្ជីដីលើកដំបូងដែលមានលក្ខណៈដាច់ដោយដុំ ឬការចុះបញ្ជីដីបំពេញបន្ថែម (ក្នុង១ក្បាលដី) | | | | | |
| លរ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរិមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
| | ២.១ ដីផលិតកម្មកសិកម្ម | | | | |
| ២៧៨ | ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងរបស់ខេត្តកណ្ដាល ព្រះសីហានុ និងសៀមរាប | ៤០០ ០០០ | ៦០ថ្ងៃ | | បើលើសពី១ហិកតាបន្ថែម៤០ ០០០ រៀល ក្នុង១ហិកតាដែល លើស(ទំហំដែលគិតជា ចំនួនគត់មិនគិត ចំនួនក្បៀស) |

[50] សារាចរណែនាំលេខ១៤, ដំណាក់កាលទី៥។

[51] ប្រកាសរួមស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦៥៨ សហវ.ប្រក, ០៧ កក្កដា ២០១៧, ឧបម្ព័ន្ធ

| | | | | | |
|---|---|---|---|---|---|
| ២៧៩ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ព្រះសីហានុ និង សៀមរាប | ៣០០ ០០០ | ៦០ថ្ងៃ | | បើលើសពី៥ហិកតា បន្ថែម៣០ ០០០ រៀល ក្នុង១ហិកតា ដែល លើស(ទំហំ ដែលគិតជា ចំនួន គត់មិនគិត ចំនួន ក្បៀស) |
| ២៨០ | ដីជនបទ ឬដីក្រៅ ក្រុង | ២០០ ០០០ | ៦០ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៥០ ០០០ រៀលក្នុង ១ហិកតា ដែលលើស(ទំហំ ដែលគិតជាចំនួន គត់មិនគិតចំនួន ក្បៀស) |
| | ២.២ ដីលំនៅដ្ឋាន ឬដីសាងសង់ | | | | |
| ២៨១ | ដីក្នុងរាជធានីភ្នំពេញ ឬដីក្នុងក្រុងរបស់ខេត្ត កណ្ដាល ព្រះសីហានុ និងសៀមរាប | ៦០០ ០០០ | ៦០ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៨០ ០០០ រៀល ក្នុង១ហិកតា ដែល លើស(ទំហំ ដែលគិតជា ចំនួន គត់មិនគិត ចំនួន ក្បៀស) |
| ២៨២ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហានុ និង ខេត្តសៀមរាប | ៤០០ ០០០ | ៦០ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៦០ ០០០ រៀល ក្នុង១ហិកតា ដែល លើស(ទំហំ ដែលគិតជា ចំនួន |

| | | | | | |
|---|---|---|---|---|---|
| | | | | | គត់មិនគិត ចំនួនក្បៀស) |
| ២៨៣ | ដីជនបទ ឬដីក្រៅក្រុង | ២០ ០០០ | ៦០ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៣០ ០០០ រៀល ក្នុង១ហិកតា ដែល លើស(ទំហំដែលគិតជា ចំនួនគត់មិនគិត ចំនួនក្បៀស) |

### ២.១.២ លទ្ធផលនៃការចុះបញ្ជី

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនៅក្នុងខេត្តកណ្តាល ក្នុងឆ្នាំ២០១៨ សម្រេចចេញប័ណ្ណបានចំនួន៦,១៨៧ប័ណ្ណ ប្រៀបធៀបនឹងឆ្នាំ២០១៧បានចំនួន៣,១១៩ប័ណ្ណ កើនឡើងចំនួន៩៧% (សរុបតាំងពីចាប់ផ្តើមអនុវត្តសម្រេចបានចំនួន១៨៧,១៧២ប័ណ្ណ)។[52]

## ២.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ញត្តិគោលដែលមានចែងក្នុងមាត្រា២២៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយត្រូវបានអនុវត្តនីតិវិធីចុះបញ្ជីគឺផ្អែកតាមអនុក្រឹត្យលេខ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធី និងការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ យោងតាមខ្លឹមសារ និងអត្ថន័យនៃបទប្បញ្ញត្តិនេះ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នឹងត្រូវអនុវត្តទៅលើគ្រប់ក្បាលដី( ទាំងរដ្ឋ និងឯកជន) ដែល ស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ បន្ទាប់ពីមានការឯកភាពពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្ត ក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យនោះ។[53]

[52] របាយការណ៍បូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល

[53] អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅ គោលបញ្ជីដីធ្លី, លេខ៤៦ អនក្រ/បក, ៣១ ឧសភា ២០០២, មាត្រា២ (តទៅហៅថាអនុក្រឹត្យលេខ៤៦)។

### ២.២.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ផ្អែកតាមសារាចរណែនាំលេខ០០១ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ) ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវធ្វើឡើងជា៥ដំណាក់កាលគឺ ការត្រៀមរៀបចំ (២.២.១.១) កិច្ចប្រតិបត្តិការបច្ចេកទេស (២.២.១.២)ការបិទផ្សាយជាសាធរណៈនូវឯកសារនៃការវិនិច្ឆ័យ(២.២.១.៣) ការសម្រេចលើឯកសារ (២.២.១.៤) និងការចេញប័ណ្ណ (២.២.១.៥)។

#### ២.២.១.១ ការត្រៀមរៀបចំ

នៅក្នុងដំណាក់កាលដំបូង នៃដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺបន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្ត ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពណ៌នា ឬតាមរបៀបទាំងពីរ។[54]

នៅពេលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ឲ្យទៅបំពេញភារកិច្ចនៅក្នុងតំបន់វិនិច្ឆ័យនោះ។ ទន្ទឹមនឹងនេះ មន្ទីររៀបចំដែលដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រុងពាក់ព័ន្ធនឹងតំបន់វិនិច្ឆ័យ ក៏ត្រូវចាត់តាំងមន្ត្រីម្នាក់ឲ្យទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីជូនអភិបាលខេត្ត ក្រុង ដើម្បី បញ្ចូលជាសមាជិកនៃគណៈកម្មការរដ្ឋបាលផងដែរ។[55]

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វិការវិនិច្ឆ័យនោះ។[56] យោងតាមមាត្រា៣ នៃអនុក្រឹត្យលេខ៤៦ គណៈកម្មការរដ្ឋបាលមានសមាសភាពដូចខាងក្រោម៖

តារាង២៖ សមាភាពមន្ត្រីគណៈកម្មការរដ្ឋបាល

| | |
|---|---|
| តំណាងអភិបាលខេត្តរាជធានី | ជាប្រធាន |
| មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |

54 សារាចរណែនាំស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ០០១ ដនស/សជ, ១៩ សីហា ២០០២, ដំណាក់កាលទី១ ចំណុចទី១ (តទៅហៅថាសារាចរណែនាំលេខ០០១)។

55 សារាចរណែនាំ០០១, ដំណាក់កាលទី១ ចំណុចទី២។

56 អនុក្រឹត្យលេខ៤៦, មាត្រា៣។

| | |
|---|---|
| មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត រាជធានី | ជាសមាជិក |
| អភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាង | ជាសមាជិក |
| មេឃុំ ចៅសង្កាត់ ឬតំណាង | ជាសមាជិក |
| មេភូមិ ឬតំណាង | ជាសមាជិក |
| ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ២រូប | ជាសមាជិក |

តាមមាត្រាដដែលនេះគណៈកម្មការរដ្ឋបាលមានភារកិច្ច បិទផ្សាយជាសាធារណៈនូវ ប្លង់សុរិយោដីជាអាទិ៍ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីទទួលបណ្តឹងតវ៉ាធ្វើការ ស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យ សម្បត្តិរដ្ឋ។

អភិបាលរាជធានី ខេត្ត ត្រូវធ្វើរលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឲ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងតិច៧ (ប្រាំពីរ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ។ បន្ទាប់មកអភិបាលរាជធានី ខេត្ត ត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំឲ្យសាធារណៈជនដឹងយ៉ាងតិច ៣ (បី) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយឃើញ នៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់[57]។ សេចក្តីជូនដំណឹងនេះ មានគោលបំណងឲ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ដី ព្រមទាំងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ បានយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីមកចូលរួមផ្តល់ព័ត៌មាន ឯកសារ និងភស្តុតាងសំខាន់ៗ ទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី និងអត្តសញ្ញាណនៃម្ចាស់ដី។[58]

### ២.២.១.២ កិច្ចប្រតិបត្តិការបច្ចេកទេស

ក្នុងដំណាក់កាលនេះការងារនៃការវិនិច្ឆ័យត្រូវបានបែងចែកជា ២ផ្នែក គឺការងារវាល (ក) និងការងារនៅការិយាល័យ (ខ)។

[57] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦អនក្រ/បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយិដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២អនក្រ/បក, ៩ មិថុនា ២០០៩, មាត្រា៦ (តទៅហៅថាអនុក្រឹត្យលេខ១២២)។
[58] សារាចរណែនាំលេខ០០១, ដំណាក់កាលទី១ ចំណុចទី៦។

ក.ការងារវាល

ការងារនេះស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ។ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដោយមានការសហការពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ចៅសង្កាត់)។

ការកំណត់ព្រំដី មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ ព្រំដីក្នុង តំបន់ វិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលចាប់ផ្តើមនឹងធ្វើការវិនិច្ឆ័យឲ្យបានមុន៣ (បី) ថ្ងៃយ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឲ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់ នៃអចលនវត្ថុរបស់ខ្លួនតាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង។ បន្ទាប់មកមន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចនលវត្ថុ ទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ មន្ត្រីកំណត់ព្រំដី ត្រូវគោរពគោលការណ៍ដូចជា៖ត្រូវបានកំណត់យោងតាមការព្រមព្រៀងរវាង ម្ចាស់នៃក្បាលដីដែលជាប់ព្រំ បើការព្រមព្រៀងមិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាននោះ ព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូបជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី។ ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់ នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់តាមការបកស្រាយខាងលើ។ វិវាទទាំងអស់អំពីព្រំប្រទល់ដែលមិន អាចដោះស្រាយបានក្នុងពេលកំណត់ព្រំដីត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួល និងដោះស្រាយវិវាទក្រោមមាត្រា១២ នៃអនុក្រឹត្យនេះ។[59]ការវាស់វែង បន្ទាប់ពីកំណត់ព្រមដីរួចមកមន្ត្រីវាស់វែង ត្រូវកំណត់ការងារវាស់វែងដែលជា តម្រូវ ការក្នុងការកសាងប្លង់សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ។[60]

ការវិនិច្ឆ័យ មន្ត្រីវិនិច្ឆ័យមានសិទ្ធិសាកសួរព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ។ មន្ត្រីវិនិច្ឆ័យអាចអញ្ជើញជនពាក់ព័ន្ធ ឲ្យផ្តល់ចម្លើយដោយផ្ទាល់មាត់ឯកសារ ឬភស្តុតាងផ្សេងៗដែលពាក់ព័ន្ធនឹងការវិនិច្ឆ័យ។ ប្រមូលរាល់ឯកសារភស្តុតាង និងព័ត៌មានផ្សេងៗដែលទាក់ទងក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលទម្រង់បែបបទនៃការប្រមូល ទិន្នន័យក្បាលដីរួចឲ្យអ្នកកាន់កាប់ដីផ្តិតមេដៃ ហើយមន្ត្រីនោះត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ។ ករណីមានវិវាទកើតឡើងទាក់ទងនឹងព្រំប្រទល់ក្បាលដី

[59] អនុក្រឹត្យលេខ១១២២, មាត្រា៧។

[60] អនុក្រឹត្យលេខ៤៦, មាត្រា៨។

មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីថាជាដីមានទំនាស់។[61]

សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកកាន់កាប់ ឬអ្នកតំណាងស្របច្បាប់៖អ្នកទាំងនេះមានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យតាមរយៈ ការផ្តល់ព័ត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំដល់អ្នកជំនាញ។ ក្នុងពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ ពួកគាត់អាចមានសិទ្ធិជំទាស់តវ៉ាប្រសិនបើខ្លួនយល់ថា ទិន្នន័យដែល មន្ត្រីបានកត់ត្រាចូលក្នុងទម្រង់បែបបទ នៃការប្រមូលទិន្នន័យមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ ខ្លួន។

អំពីភារកិច្ចរបស់អាជ្ញាធរដែនដី៖ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណៈសម្បត្តិ ងាយស្រួលសហការបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយមានប្រតិបត្តិការបច្ចេក ទេសរដ្ឋបាលគតិយុត្តដើម្បីធ្វើឲ្យសម្រេចនូវការអនុវត្តនីតិវិធីដែលប្រព្រឹត្តនៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ។ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារដែលមានប្លង់ សុរិយោដីនិងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំសង្កាត់ណាមួយ ឬតំណាងស្របច្បាប់របស់ខ្លួនត្រូវមានតាម កាល កំណត់ និងតម្រូវការជាក់ស្តែងនៃការងារ។[62]

ខ.ការងារនៅការិយាល័យ

រាល់ទិន្នន័យដែលប្រមូលបានពីការងារវាល ជាចាំបាច់ត្រូវបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី ព្រមទាំងរៀបចំចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដល់ម្ចាស់ដី។[63]

### ២.២.១.៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃវិនិច្ឆ័យ

អភិបាលរាជធានី ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីតាមសំណើរបស់គណៈកម្មការរដ្ឋបាល។ ការជូនដំណឹងអាចធ្វើឡើងតាមគ្រប់មធ្យោបាយដូចជាតាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រូបភាព បិទផ្សាយឬតាមឧគ្ឃោសនសព្ទ។ ការបិទផ្សាយជាសាធារណៈមាន រយៈពេល ១៥ ថ្ងៃ ហើយត្រូវធ្វើនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងនៃតំបន់ធ្វើការវិនិច្ឆ័យដូចជា ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ-សង្កាត់ សាលាស្រុក។[64]

[61] សារាចរណែនាំលេខ០០១, ដំណាក់កាល២ ចំណុច១.១.២។

[62] សារាចរណែនាំលេខ០០១, ដំណាក់កាល២ ចំណុច១.១.២។

[63] សារាចរណែនាំលេខ០០១, ដំណាក់កាល២ ចំណុច២

[64] អនុក្រឹត្យលេខ១២២, មាត្រា១១។

ក្នុងអំឡុងពេលបិទផ្សាយមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវណែនាំមន្ត្រីដែលទទួលខុសត្រូវការងារជំនាញនីមួយៗ ឲ្យប្រចាំការនៅកន្លែងបិទផ្សាយរាល់ថ្ងៃទាំងថ្ងៃឈប់សំរាកទាំងថ្ងៃបុណ្យផ្សេងៗ ដើម្បីរងចាំពន្យល់ ឬបំភ្លឺខ្លឹមសារនៃទិន្នន័យ បកស្រាយចម្ងល់ផ្សេងៗដែលទាក់ទង នឹងឯកសារដែលបានបិទផ្សាយ។ ទន្ទឹមនឹងនេះគណៈកម្មការរដ្ឋបាលក៏ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រង ការងារតំបន់វិនិច្ឆ័យ និងមន្ត្រីមូលនៅដ្ឋានចាំបាច់ជាអាទិ៍ ឬបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាតាមគោលការណ៍កំណត់។

សាមីអ្នកកានកាប់ដី ឬអ្នកតំណាងស្របច្បាប់ របស់ជននេះ ដែលមិនទាន់យល់ស្របតាមការសម្រេចបណ្តោះអាសន្នរបស់មន្ត្រីជំនាញនៅពេលប្រតិបត្តិកំណត់ព្រំដី ឬវិនិច្ឆ័យ មានសិទ្ធិប្តឹង ជំទាស់ ឬប្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ ដើម្បីឲ្យគណៈកម្មការលើកយកដោះស្រាយឡើងវិញ។ ករណីមិនអាចដោះស្រាយបានគណៈកម្មការរដ្ឋបាលត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីធ្វើការដោះស្រាយបន្ត។ បណ្តឹងនីមួយៗត្រូវបានកត់ត្រាដោយឡែកពីគ្នា ហើយត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកម្មនៃបណ្តឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹងឈ្មោះ និងហត្ថលេខាមន្ត្រីទទួលកត់ត្រា និងមានបញ្ជាក់ការដឹងឮពីមេឃុំ ចៅសង្កាត់ ឬតំណាងស្របច្បាប់របស់ជននេះ។ ករណីមិនមានការជំទាស់ ឬតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកំណត់ត្រានោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន លើកលែងចំពោះករណីដែលសាមីអ្នកកាន់កាប់ដី ឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពី មូលហេតុដែលមិនបានធ្វើការជំទាស់ ឬតវ៉ាក្នុងអំឡុងពេលនៃការបិទផ្សាយសាមីជនដាក់ពាក្យ បណ្តឹងទៅ គណៈកម្មការសុរិយោដីដើម្បីដោះស្រាយតាមនីតិវិធីដែលបានកំណត់។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិកែប្រែតម្រូវចំពោះកំហុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពល ដល់ផលប្រយោជន៍អ្នកដទៃ។ ចំពោះការកែតម្រូវណាដែលនាំឲ្យជះឥទ្ធិពលដល់ប្រយោជន៍អ្នកដទៃ អាចធ្វើការកែសម្រួលបានលុះត្រាតែមានការយល់ព្រមពីជនដែល មានប្រយោជន៍ពាក់ព័ន្ធនោះ។[65]

### ២.២.១.៤ ការសម្រេចលើឯកសារ

បន្ទាប់ពីរយះពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យគណៈកម្មការរដ្ឋបាលត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារចំពោះលទ្ធផលដែលបានសម្រេចដូចជាៈ

[65] សារាចរណែនាំលេខ០០១, ដំណាក់កាលទី៣។

ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ ចំនួនក្បាលដីដែលមិនត្រូវបាន ចេញចេញប័ណ្ណជូនដោយការកាន់កាប់ដីរដ្ឋចាប់ផ្តើមក្រោយការចូលជាធរមាននៃច្បាប់ភូមិបាល ចំនួន ក្បាលដីដែលមានលក្ខណៈត្រឹមត្រូវនិងគ្មានវិវាទ ចំនួនក្បាលដីដែលមានវិវាទ ចំនួនក្បាលដី មានវិវាទដែលគណៈកម្មការរដ្ឋបាលដោះស្រាយរួចតាមការព្រមព្រៀង ចំនួនក្បាលដីមានវិវាទ ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីនិងចំនួនក្បាលដីដែលកំពុងមានបណ្តឹងនៅតុលាការ។[66]

លើសពីនេះទៅទៀត ត្រូវធ្វើការវាយតម្លៃលើកសំណើផ្តល់កម្មសិទ្ធិលើដី ឬអចលនវត្ថុតាមប្រភេទកម្មសិទ្ធិភោគៈ សម្បទាន ឬរក្សាទុកជាដីរដ្ឋជូនកម្មសិទ្ធិករ ភោគី ឬអ្នកកាន់កាប់ដោយយោងទៅតាមច្បាប់បទដ្ឋាន គតិយុត្តពាក់ព័ន្ធផ្សេងទៀត និងឯកសារ ឬភស្តុតាងដែលប្រមូលបាន។ ក្រោយពីប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវបានកែប្រែរួចះមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី និងបញ្ជី ឈ្មោះម្ចាស់ដី ប្រធានគណៈកម្មការរដ្ឋាបាលត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដីនិងបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ,ប្រធានមន្ទីរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងត្រូវចុះហត្ថ លេខាបំព្រួញលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ និងរបាយការណ៍ស្តីពីលទ្ធផល នៃការវិនិច្ឆ័យត្រង់ចំណុចហត្ថលេខាអភិបាលខេត្ត ក្រុង,អភិបាល ខេត្ត ក្រុងត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដីនិងរបាយការណ៍ស្តី ពីលទ្ធផល នៃការវិនិច្ឆ័យ ករណីមិនឯកភាពត្រូវបញ្ជាក់ពីលទ្ធ ផលឲ្យ បានច្បាស់លាស់,រដ្ឋមន្ត្រីរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះហត្ថលេខាសម្រេចជាផ្លូវការលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការ វិនិច្ឆ័យ។[67]ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាសម្រេចយល់ព្រមរួចហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ជាប់ជាស្ថាពរ និងត្រូវ បានចាត់ទុកជាឯកសារផ្លូវការតាមច្បាប់ ចំពោះក្បាលដីមិនទាក់ទងវិវាទ។ ចំពោះក្បាលដីដែលមានវិវាទដែលមិនទាន់ដោះស្រាយរួចជាស្ថាពរត្រូវបន្តការដោះស្រាយនៅគណៈកម្មការសុរិយោដី ឬតុលាការ។

### ២.២.១.៥ ការចេញប័ណ្ណ

នៅពេលនីតិវិធីនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និងឯកសារ វណបទាំងអស់ ត្រូវបានបញ្ជូនទៅរដ្ឋបាលសុរិយោដី ដើម្បីចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង។

គោលការណ៍នៃការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងចេញប័ណ្ណសម្គាល់សិទ្ធិ

[66] សារាចរណែនាំលេខ០០១, ដំណាក់កាលទី៤ ចំណុចទី១។

[67] សារាចរណែនាំលេខ០០១, ដំណាក់កាលទី៤ ចំណុចទី២

កាន់កាប់អចលនវត្ថុ៖

១.ចេញវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប័ណ្ណកម្មសិទ្ធិ)ចំពោះក្បាលដីឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់ភូមិបាល (មាត្រា១០វាក្យខណ្ឌទី១ នៃច្បាប់ភូមិបាល)។

២.ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ)ចំពោះក្បាលដីឬ អចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធីនិងមិនមានការជំទាស់ហើយមាន រយៈពេលតិចជាង៥ឆ្នាំមុនច្បាប់ភូមិបាលចូលជាធរមាន។ ប័ណ្ណប្រភេទនេះអាចប្តូរយក វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុនៅពេលដែលរយៈពេលនៃការកាន់កាប់ ដី ឬអចលនវត្ថុនោះបានគ្រប់ ៥ ឆ្នាំ ឬលើស។

៣.អាចចេញប័ណ្ណជូនចំពោះតែក្បាលដីឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹង វិវាទ។

៤.ការប្រគល់ប័ណ្ណ ត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នក ប្រគល់និងកត់ឈ្មោះរួចផ្តិតមេដៃអ្នកទទួល ទុកជាភស្តុតាង។ ការប្រគល់ប័ណ្ណត្រូវ ប្រព្រឹត្តទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដី មិនត្រូវបាន អនុញ្ញាតឲ្យប្រគល់ប័ណ្ណ ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង ម្ចាស់សិទ្ធិទទួលមរណៈភាព អវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាពដែល ច្បាប់ទទួលស្គាល់ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស។ករណី ពិសេស និងចាំបាច់ម្ចាស់សិទ្ធិ អាចដាក់ពាក្យសុំប័ណ្ណបានតែត្រូវបញ្ជាក់ពីហេតុដែល មិនអាចមក ទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឲ្យប្រគល់នៅគេហដ្ឋាន របស់កម្មសិទ្ធិករ ភោគីដោយមន្ត្រីសុរិយោដីយ៉ាងតិចពីរនាក់។

៥.នៅពេលទទួលប័ណ្ណថ្មីម្ចាស់ដីឬអចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិ លើដីឬអចលនវត្ថុជូនមន្ត្រីសុរិយោដីប្រសិនបើមាន។

៦.ចំពោះនីតិបុគ្គលប័ណ្ណប័ណ្ណត្រូវចុះឈ្មោះអង្គភាពមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ចំពោះដីសម្ហូភាពដូចជាវត្តឬសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះវត្ត ឬសហគមន៍ផងដែរ មិនអាចចុះឈ្មោះអ្នកតំណាង ឡើយ។[68]

[68] សារាចរណែនាំលេខ០០១, ដំណាក់កាលទី៥។

ក.តម្លៃសេវាសាធារណៈនៃការចុះបញ្ជី

យោងតាមប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តម្លៃសេវាសាធារណៈនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានកំណត់ដូចនៅក្នុងតារាងខាងក្រោម៖

តារាង៣៖ តម្លៃសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ[69]

| ២.សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | |
|---|---|---|---|---|---|
| ការចុះបញ្ជីដីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ (ក្នុង១ម$^{២}$) | | | | | |
| លរ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរិមានៃការផ្តល់សេវា | សុភលភាព (អចិន្ត្រៃយ៍) | សេចក្តីផ្សេងៗ |
| ២៧២ | ដីផលិតកម្មកសិកម្មក្រៅរាជធានីភ្នំពេញ | ១ | ១០០ថ្ងៃ | | ១០០រៀល សម្រាប់ដីតូចជាង១០០ ម$^{២}$ |
| ២៧៣ | ដីលំនីដ្ឋាន ឬដីសាងសង់នៅជនបទ | ១០ | ១០០ថ្ងៃ | | |
| ៣៧៤ | ដីលំនៅដ្ឋាន ឬដីសាងសង់ក្នុងទីប្រជុំជនស្រុក | ២០ | ១០០ថ្ងៃ | | |
| ២៧៥ | លំនៅដ្ឋាន ឬដីសាងសង់ក្នុងទីប្រជុំជនក្រុង | ២៥០ | ១០០ថ្ងៃ | | |
| ២៧៦ | ដីផលិតកម្ម កសិកម្ម | ២៥០ | ១០០ថ្ងៃ | | |

[69] ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦៤៨ សហវ.ប្រក, ០៧ កក្កដា ២០១៧, ឧបម្ព័ន្ធ។

| | | | | | |
|---|---|---|---|---|---|
| | នៅរាជធានីភ្នំពេញ | | | | |
| ២៧៧ | លំនៅដ្ឋាន ឬដីសាងសង់នៅរាជធានីភ្នំពេញ | ៥០០ | ១០០ថ្ងៃ | | |

**២.២.២ លទ្ធផលនៃការចុះបញ្ជី**

គួរកត់សម្គាល់ថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងខេត្តកណ្តាលរហូតដល់ឆ្នាំ២០១៨បាន៣៩៩ភូមិ។ ក្នុងឆ្នាំ២០១៨សម្រេចបានលទ្ធផល បញ្ចូលទិន្នន័យក្បាលដី បានចំនួន៨៩០៦ក្បាលដី (សរុបតាំងពីពេលចាប់ផ្តើមអនុវត្តបាន ២២៩,៥៥២ក្បាលដី) បិទផ្សាយជាសាធារណៈបានចំនួន ៥៩៣៦ ក្បាលដី (សរុបតាំងពីពេលចាប់ផ្តើមអនុវត្តបាន ២១២,២៤០ក្បាលដី) ចែកប័ណ្ណជូនប្រជាពលរដ្ឋបានចំនួន៣៣៧២ប័ណ្ណ(សរុបតាំងពីចាប់ផ្តើមអនុវត្ត បានចំនួន១៧៩,៨១០ ប័ណ្ណ)។[70]

**២.២.៣ ផលប្រយោជន៍នៃការចុះបញ្ជី**

រាល់ការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាលគ្រប់ទម្រង់គឺ សុទ្ធតែមានគោលដៅក្នុងការរក្សានៅផលប្រយោជន៍សាធារណៈ និងឯកជន និងមានគោលបំណងដូចគ្នាគ្រប់ខេត្តក្រុង ដោយមានចក្ខុវិស័យតែមួយរបស់រដ្ឋាភិបាល។ ការចុះបញ្ជីដីធ្លីបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ និងសង្គមដូចជា ធានា និងរក្សាភាពជាម្ចាស់កម្មសិទ្ធិអចលនវត្ថុ កាត់បន្ថយ ឬលុបបំបាត់ទំនាស់លើដីធ្លី ធានានូវសុវត្ថិភាពក្នុងការផ្ទេរសិទ្ធិអចលនវត្ថុ ថែមទាំងបង្កើនលទ្ធភាពក្នុងការរកឥណទានសម្រាប់ការធ្វើអាជីវកម្មកាន់តែប្រសើរឡើង និងធ្វើឲ្យប្រាក់ចំណូលជាតិកើនឡើងផងដែរតាមរយៈការបង់ពន្ធ។

[70] របាយការណ៍បូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល, ៥០ឃុំ/សង្កាត់ ៦ក្រុង/ស្រុក។

# ជំពូកទី៣

# បញ្ហាប្រឈមនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល

ជំពូកនេះពិភាក្សាពីបញ្ហាប្រឈមដែលបានកើតឡើង នៅខេត្តកណ្ដាលក្នុងពេលអនុវត្តការចុះបញ្ជីដីធ្លី ទាំងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ បញ្ហាប្រឈម គឺជាឧបសគ្គមួយដ៏ចម្បងមួយដែលត្រូវជម្នះឲ្យបានក្នុងការរៀបចំដំណើរការចុះបញ្ជីដីធ្លីឲ្យបានប្រសើរឡើង។ បញ្ហាប្រឈមដែលបានកើតឡើងនៅពេលអនុវត្តការចុះបញ្ជីដីធ្លីនៅខេត្តកណ្ដាល រួមមានស្ថានភាពតំបន់ភូមិសាស្ត្រ(៣.១) ធនធានមនុស្ស(៣.២) ហិរញ្ញវត្ថុ(៣.៣) និងឧបករណ៍វាស់វែង(៣.៤) ។

## ៣.១. ស្ថានភាពតំបន់ភូមិសាស្ត្រ

តំបន់ភូមិសាស្ត្រក្នុងខេត្តកណ្ដាលមានភាពស្មុកស្មាញច្រើន ដែលធ្វើអោយមានការលំបាកដល់មន្ត្រីសុរិយោដីក្នុងការអនុវត្ត។ ផលវិបាកទាំងនោះមានទីតាំង ភូមិសាស្ត្រក្រៅទីប្រជុំជន និងទីតាំងភូមិសាស្ត្រទីប្រជុំជន។[71] ភូមិសាស្ត្រក្រៅទីប្រជុំជន គឺកន្លែងដែលសំបូរព្រៃ នៅតាមព្រំក្បាលដីនីមួយៗពិបាកដាក់ឧបករណ៍វាស់វែង និងកន្លែងខ្លះឧស្សាហ៍លិចទឹក(ដីស្រែចំការ) តំបន់ដែលមានផ្លូវពិបាកចូលទៅដល់ និងនៅតាមតំបន់ខ្លះទៀតដែលនៅជាប់តាមមាត់ទន្លេ ព្រែក ស្ទឹង បឹង នឹងអូរជាដើម។ ប្រភេទដីស្រែចំការខ្លះធំដែលមានរូបរៀងមានជ្រុងច្រើនធ្វើឲ្យមន្ត្រីវាលប្រើពេលវេលាច្រើនក្នុងការវាស់វែង។

តំបន់ទីប្រជុំជនវិញគឺ ភូមិសាស្ត្រនេះមានភាពលំបាកច្រើនក្នុងការវាស់វែងទីតាំងខ្លះមានភាពតូចចង្អៀត មិនមានចន្លោះ ឬចន្លោះតូច ដោយជួនកាលត្រូវប្រើដណ្ដើរទៅកំណត់ ទីតាំងដីរបស់ប្រជាពលរដ្ឋ ដែលធ្វើអោយមន្ត្រីសុរិយោដីពិបាកចូលទៅកំណត់ទំហំដី។ ជាពិសេស នៅពេលចូលមកដល់រដូវវស្សាមានភាពយឺតយ៉ាវច្រើនពេលភ្លៀងធ្លាក់គឺ ការវាស់វែងផ្អាកសិនទាល់តែភ្លៀងរាំងទើបមិនមានឧបសគ្គដល់ឧបករណ៍វាស់វែងក្នុងការរកព្រំដី។

## ៣.២ ធនធានមនុស្ស

នៅក្នុងដំណើរការចុះបញ្ជីដីធ្លី សុទ្ធតែត្រូវមានការចូលរួមសហការគ្នាយ៉ាងប្រទាក់ក្រឡា រវាងមន្ត្រីជំនាញ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ បើពុំនោះទេ ការចុះបញ្ជីមិនអាចកើតមានឡើងដោយរលូនឡើយ ប្រាកដជាជួបនូវឧបសគ្គក្នុងកិច្ចដំណើរការនេះជាក់ជាពុំខាន។ ជាក់ស្ដែងនៅក្នុងខេត្ត

[71] បទសម្ភាសជាមួយនឹងលោកអ៊ឹម ពុទ្ធារ៉ា មន្ត្រីវាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សុរិយោដីខេត្តកណ្ដាល (ទទួលបន្ទុកវាស់វែងដីធ្លីនៅ ខេត្តកណ្ដាល), បទសម្ភាសផ្ទាល់ ( ៤ មិថុនា ២០១៩) (តទៅហៅថាបទសម្ភាសជាមួយមន្ត្រីវាល)។

កណ្តាលក៏បានជួបប្រទះនូវឧបសគ្គផងដែរ គឺ មានបញ្ហាមន្ត្រីជំនាញ និងបញ្ហាប្រជាពលរដ្ឋ។ នៅក្នុងកិច្ចដំណើរការចុះបញ្ជីគឺ ត្រូវមានមន្ត្រីជំនាញផ្សេងៗ ដើម្បីអនុវត្ត កិច្ចការនេះ ដូចជាមន្ត្រីជំនាញខាងកំណត់ព្រំដី មន្ត្រីវាស់វែង មន្ត្រីខាង ទិន្នន័យ-ល-។

ចាប់តាំងពីមានការរៀបចំឲ្យមានការចុះបញ្ជីដីធ្លីមក បញ្ហាមន្ត្រីជំនាញនៅតែជាកង្វល់ក្នុងនីតិវិធីនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល ដូចជាកង្វះខាតមន្ត្រី សមត្ថភាពមន្ត្រីមួយចំនួនមានចំណេះដឹងមិនសូវមានបទពិសោធន៍ ធ្វើការធ្វេសប្រហែសពេលវាស់វែងដីជូនប្រជាពលរដ្ឋហើយ បានចុះលេខក្បាលដីច្រឡំ កំណត់ព្រំរដ្ឋបាល ភូមិ/ឃុំ មិនច្បាស់លាស់ នាំឲ្យមានការស្មុកស្មាញក្នុង ការចេញប័ណ្ណកម្មសិទ្ធិ មួយវិញទៀត គឺបញ្ហាកង្វះខាតសម្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ កំពុងតែប្រឈមនិងតួនាទី និងការងារដ៏ច្រើនដែលពួកគាត់មិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញការងារបាន។[72]

ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិត មិនយល់ដឹងអំពីគោលការណ៍នៃការចុះបញ្ជីជាហេតុធ្វើឲ្យគាត់មិនចង់ចុះបញ្ជី ពីព្រោះនៅពេលចុះបញ្ជី ចេញប័ណ្ណកម្មសិទ្ធិ តម្រូវឲ្យគាត់បង់ប្រាក់សម្រាប់ដំណើរការនីតិវិធី ដូចនេះម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់មួយចំនួនមិនបានយកចិត្តទុកដាក់លើការចុះបញ្ជីឡើយ។ ការចូលរួមរបស់ប្រជាពលរដ្ឋ អាចកើតមានលុះត្រាតែមានចំណេះដឹងជាមូលដ្ឋានទៅលើដំណើរការនីតិវិធីទាក់ទងទៅនឹងការចុះបញ្ជីដីធ្លី ហើយចំណេះដឹងផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យនេះ។ អសមត្ថភាពចំណេះដឹងប្រជាពលរដ្ឋនៅពេលបច្ចុប្បន្ន គឺជាឧបសគ្គដែលអាចនាំឲ្យប្រជាពលរដ្ឋមិនបានចូលរួមក្នុងការដំណើរការនីតិវិធីនេះ។ ក្បាលដីខ្លះម្ចាស់មិនចូលរួមធ្វើឲ្យប៉ះពាល់ដល់ក្បាលដីនៅជាប់ព្រំដីនោះ និងមិនជួយថែរក្សាបង្គោលប្រឹថ ដែលបានបោះរួចធ្វើឲ្យលំបាកក្នុងការវាស់វែង។ ជាពិសេសទំនាស់ព្រំក៏កើនឡើងដោយប្រជាពលរដ្ឋ មិនចេះយោគយល់គ្នាធ្វើឲ្យបាត់ផលប្រយោជន៍រៀងៗខ្លួន ប្រសិនបើប្រជាពលរដ្ឋយល់ដឹងអំពី ច្បាប់ចេះអធ្យាស្រ័យគ្នា និងទទួលបានផលប្រយោជន៍ទាំងសងខាង។ មិនតែប៉ុណ្ណោះប្រជាពលរដ្ឋមួយចំនួនបានកាន់កាប់ដីដោយបំពានទៅលើដីផ្លូវថ្នល់ ហើយទាមទារឲ្យចេញប័ណ្ណកម្មសិទ្ធិជូនខ្លួន ដោយខុសច្បាប់នោះ ដែលនាំឲ្យមន្ត្រីមានបញ្ហា គឺធ្វើឲ្យមានភាពយឺតយូរដល់ការចុះបញ្ជី។[73]

## ៣.៣ ហិរញ្ញវត្ថុ

ហិរញ្ញវត្ថុនៅក្នុងការចុះបញ្ជីខេត្តកណ្តាលគឺ នៅជាបញ្ហាចោទនៅឡើយដោយការស្នើសុំមានរយៈពេលយូរ។ នៅពេលម៉ាស៊ីនTotal កំណត់ព្រំដល់ពេលកែសម្រួលកម្មវិធីថ្មីដែលប្រើថវិកាប

[72] បទសម្ភាសជាមួយនឹងលោកទៀង កុស្សរៈអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សុរិយោដីខេត្តកណ្តាល (ទទួលបន្ទុកការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ខេត្តកណ្តាល), បទសម្ភាសផ្ទាល់ ( ១១ ឧសភា ២០១៩)។
[73] បទសម្ភាសជាមួយមន្ត្រីវាល។

ស់រដ្ឋ ហើយកញ្ចប់ថវិកាមានការយឺតយ៉ាវធ្វើឲ្យមន្ត្រីប្រើឧបករណ៍ទាំងនោះមានឧបសគ្គច្រើន ក្នុងការកំណត់ព្រំដី។[74] ហេតុផលមួយចំនួនដែលជាឧបសគ្គដល់ការចុះបញ្ជីដី គឺប្រាក់បៀវត្សន៍ របស់អាជ្ញាធរមូលដ្ឋាន នៅមានកម្រិតតិចមិនអាចផ្គត់ផ្គង់ជីវភាពរស់នៅគ្រួសារបាន កត្តាទាំងនេះ ហើយគឺជាបាតុភូតធ្វើឲ្យការអនុវត្តភារកិច្ចរបស់ពួកគាត់ពុំមានប្រសិទ្ធភាពដែលធ្វើឲ្យពួកគាត់ងាកទៅធ្វើការងារផ្សេងៗវិញ។ បញ្ហាទាំងនេះហើយទើបការអនុវត្តការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាល កន្លងមកមានភាពយឺតយ៉ាវហើយប្រើររយៈពេលច្រើនក្នុងការចេញវិញ្ញាបនបត្រជូនប្រជាពលរដ្ឋ។

## ៣.៤ ឧបករណ៍វាស់វែង

ការប្រព្រឹត្តទៅក្នុងការវាស់វែងជាចាំបាច់ត្រូវមានឧបករណ៍វាស់វែង ដើម្បីបង្កើនភាពងាយស្រួលដល់ការរកព្រំដី ហើយឧបករណ៍វាស់វែងដែលប្រើសម្រាប់កំណត់ព្រំដីមានដូចជា ខ្សែម៉ែត្រប្រឹថកែងបង្គោលតំរង់ ម៉ាស៊ីន Total Station GPS ឬDGPS ជាដើម។ តួយ៉ាងឧបករណ៍ មួយចំនួននៅខេត្តកណ្តាលមានចំនួនតិចតួចហើយខ្លះទៀត មានសភាពចាស់ខ្លាំងហើយតម្រូវការប្រើច្រើន ពីមួយកន្លែងទៅមួយកន្លែងគ្មានការផ្លាស់ប្តូរឧបករណ៍ ដូចនេះហើយឧបករណ៍ខ្លះខូច រយៈពេលក្នុងការជូសជុលយូរធ្វើឲ្យដំណើរការវាស់វែងមានការរអាក់អួល។[75]

[74] បទសម្ភាសជាមួយមន្ត្រីវាល។

[75] បទសម្ភាសជាមួយមន្ត្រីវាល។

# សេចក្តីសន្និដ្ឋាន

ការចុះបញ្ជីដីធ្លី មានសារៈសំខាន់ខ្លាំងណាស់ ចំពោះប្រជាពលរដ្ឋគ្រប់រូបដែលជាម្ចាស់ដីពិតប្រាកដ។ តាមរយៈប័ណ្ណកម្មសិទ្ធិ ម្ចាស់កម្មសិទ្ធិអាចយកប័ណ្ណនេះទៅប្រើប្រាស់សម្រាប់សេវាឥណទាន តាមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដើម្បីយកប្រាក់សម្រាប់បង្កើនអាជីវកម្មរបស់ខ្លួនបាន។ ប័ណ្ណកម្មសិទ្ធិ គឺជាភស្តុតាងយ៉ាងពេញលេញមួយដែលបញ្ជាក់ពីភាពស្របច្បាប់ នូវអត្តសញ្ញាណក្បាលដី អត្តសញ្ញាណម្ចាស់ដែលមានសិទ្ធិលើក្បាលដី ដូចនេះប័ណ្ណកម្មសិទ្ធិ ធានាយ៉ាងគ្រប់គ្រាន់នូវសុវត្ថិភាព ក្នុងការកាន់កាប់ និងប្រើប្រាស់ដី របស់ម្ចាស់ដី។

ចំពោះការចុះបញ្ជីដីធ្លី មានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយមានប្រាំដំណាក់កាលដូចគ្នា។ ចំណុចដែលងាយសម្គាល់ពីលក្ខណៈខុសគ្នារវាង ការចុះបញ្ជីទាំងពីរប្រព័ន្ធនេះ គឺត្រង់ថាការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ គឺជាចុះបញ្ជីតាមរយៈការដាក់ពាក្យស្នើសុំរបស់កម្មសិទ្ធិករ ដែលមិនទាន់បានចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ។ ចំណែកឯការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធវិញគឺ ជាការចុះបញ្ជីដីធ្លីទូទាំងភូមិដែលរាជរដ្ឋាភិបាលបានសម្រេច។

ការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាលបានសម្រេចនូវលទ្ធផលវិជ្ជមានដោយបានផ្តល់ប័ណ្ណជូនប្រជាពលរដ្ឋតាមតម្រូវការរបស់ពួកគាត់។ ពីមួយឆ្នាំទៅមួយឆ្នាំកំណើននៃការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិមានការកើតឡើងគួរឲ្យកត់សម្គាល់ រីឯការផ្តល់ប័ណ្ណក៏មានការកើតឡើងផងដែរដោយគិតតាំងពីពេលចាប់ ផ្តើមអនុវត្តមក ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំសម្រេចបានចំនួន ១៤៧.១៧២ប័ណ្ណ និង ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធសម្រេចបានចំនួន ២២៩.៥៥២ ប័ណ្ណ។

ដំណើរការនៃការអនុវត្តចុះបញ្ជីដីធ្លីនៅខេត្តកណ្តាលមានការរលូនទៅមុខយ៉ាងណាក្តី ក៏មានបញ្ហាមួយចំនួនដែលធ្វើឲ្យមាន ការរាំងស្ទះដល់ដំណើរការនេះផងដែរ ដូចជា បញ្ហាតំបន់ភូមិសាស្ត្រ ធនធានមនុស្ស ហិរញ្ញវត្ថុ និងឧបករណ៍វាស់វែងជាដើម។ ការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីនៅខេត្តកណ្តាលនៅមានបញ្ហាជាឧបសគ្គមួយចំនួនក្តីតែការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធនេះនៅតែអាចបន្តអនុវត្ត ទៅមុខបានយ៉ាងល្អ ហើយបានដើរតួយ៉ាងសំខាន់ក្នុងវិស័យដីធ្លី ជាពិសេសជាផ្នែកមួយល្អនៅក្នុងការកំណត់ម្ចាស់កម្មសិទ្ធិប្រកបទៅដោយភាពសុក្រឹតត្រឹមត្រូវ និងកាត់បន្ថយទំនាស់លើដីធ្លី។

# អនុសាសន៍

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គួរបង្កើនការផ្សព្វផ្សាយនានាឲ្យដល់ប្រជាពលរដ្ឋឲ្យទាន់ពេលវេលា និងឆាប់រហ័សមុនពេលចុះទៅអនុវត្ត។ ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាន ចំណេះដឹងទាក់ទងនឹងការចុះបញ្ជីដី ឬសារៈសំខាន់នៃការចុះបញ្ជីដីធ្លីរបស់ពួកគាត់ ដែលធ្វើឲ្យពួកគាត់មានសកម្មភាពចូលរួម និងបង្កភាពងាយស្រួលដល់មន្ត្រីក្នុងការវាស់វែង រៀបចំកែប្រែ ពន្លឿននីតិវិធីកុំឲ្យមានភាពស្មុកស្មាញ ហើយមានរយៈពេលខ្លីក្នុងការចុះបញ្ជី។

រាជរដ្ឋាភិបាលគួរបណ្តុះបណ្តាលមន្ត្រីជំនាញបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង និងបង្កើនកញ្ចប់ថវិកាក្នុងការចុះបញ្ជីដីធ្លី បន្ថែមនូវឧបករណ៍វាស់វែង ដែលមានលក្ខណៈទំនើប និងមានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់ដើម្បីបង្កលក្ខណៈងាយស្រួលដល់មន្ត្រីចុះវាស់វែង។ បង្កើតឲ្យមានវគ្គបណ្តុះបណ្តាល និងវគ្គសិក្សាពីបច្ចេកទេសដល់មន្ត្រីជំនាញគ្រប់ផ្នែកទាំងអស់ ដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តដោយប្រសិទ្ធភាព។

លើសពីនេះទៅទៀតរាជរដ្ឋាភិបាល គួររឹតបន្តឹងវិធានការផ្លូវច្បាប់ឲ្យកាន់តែធ្ងន់ធ្ងរចំពោះមន្ត្រីដែលអនុវត្តផ្ទុយពីការកំណត់របស់ច្បាប់។ ការអនុវត្តការចុះបញ្ជីកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័សនៅពេលដែលការអនុវត្ត របស់មន្ត្រី មានតម្លាភាព គ្មាន អំពើពុករលួយ និងយុត្តិធម៌។

# គន្ថនិទ្ទេស

**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**


ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦៤៨ សហវ.ប្រក, ៧ កក្កដា ២០១៧។

ប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរដ្ឋបាលឃុំសង្កាត់ក្នុងការចុះបញ្ជីដីធ្លី, លេខ២១៥ ប្រក/ជនស/មផ, ៩ កញ្ញា ២០០៥។

សារាចរណែនាំស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី, លេ០០១ ជនស/សជ, ១៩ សីហា ២០០២។

សារាចរណែនាំស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១៤ជន/សសរណាន, ៣០ កញ្ញា២០០៩។

សេចក្តីណែនាំស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ០៣ មិថុនា ១៩៨៩។

អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៦មាត្រា៧និងមាត្រា១១នៃអនុក្រឹត្យលេខ៤៦អនក្រ/បក, ចុះថ្ងៃទី៣១ខែឧសភាឆ្នាំ២០០២ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយិដីនិងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២អនក្រ.បក, ៩ មិថុនា ២០០៩។

អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ/បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ/បក, ៩ មិថុនា ២០១៦។

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ៥ តុលា ២០០៥។

អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្របក, ៣១ ឧសភា ២០០២។

អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ/បក, ៣១ ឧសភា ២០០២។

## សៀវភៅ និងឯកសារផ្សេងៗ

Mattew Rendall, Josee Trembly និង Patricia.ច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ (ភ្នំពេញ៖ East-West Management institute, 2005)។

ហាប់ ផល្ធី "នីតិទ្រព្យសម្បត្តិ", ២០១៥។

របាយការណ៍បូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្ដាល។

ហាប់ផល្ធី, បញ្ហានានាពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា(១២.៧.២០១០), ២, phalthy.wordpress.com (ចូលទស្សនាថ្ងៃទី១០ កក្កដា ២០១៩)។

## បទសម្ភាស

បទសម្ភាសជាមួយនឹងលោកទៀង កុស្សរៈ អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដី ខេត្តកណ្ដាល (ទទួលបន្ទុកការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ខេត្តកណ្ដាល), បទសម្ភាសផ្ទាល់ ( ១១ ឧសភា ២០១៩)។

បទសម្ភាសជាមួយនឹងលោកអ៊ឹម ពុទ្ធារ៉ា មន្ត្រីវាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តកណ្ដាល (ទទួលបន្ទុកវាស់វែងដីធ្លីនៅ ខេត្តកណ្ដាល), បទសម្ភាសផ្ទាល់ ( ៩ មិថុនា ២០១៩)។